# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងឥណទានគេហដ្ឋាន

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ឈ្មោះស្ថាប័ន៖ ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ( ABA ) សាខាខេត្តពោធិ៍សាត់


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **គី ធារី**

**សួន ពីសី**

សាស្ត្រាចារ្យណែនាំ៖

**លោក ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតជំនាន់ទី១៤ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យសេដ្ឋកិច្ចនិងគ្រប់គ្រង ឆ្នាំសិក្សា២០២០-២០២១ ដូចមានរាយនាមដូចខាងក្រោម៖

១.កញ្ញា ភី ធារី

២.អ្នកស្រី សួន ពីសី

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

-លោក ឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតដល់កូន និងខិតខំជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីថែរក្សាដល់កូនព្រមទាំងផ្គត់ផ្គង់ជាសម្ភារៈ និងថវិកាដល់ការសិក្សារបស់កូនជាដរាបរៀងមក។

-ឯកឧត្តម បណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសលោកសាស្ត្រាចារ្យ ឈាង ហ៊ុយ ដែលជាសាស្ត្រាចារ្យដឹកនាំដែលលោកបានខិតខំបង្ហាត់បង្រៀន ណែនាំ និងផ្តល់ជាឯកសារដល់យើងខ្ញុំទាំងអស់គ្នា។

-លោកនាយកធនាគារ ABA សាខាខេត្តពោធិ៍សាត់ និងបុគ្គលិកទាំងអស់ដែលបានអនុញ្ញាតឲ្យយើងខ្ញុំធ្វើបទសម្ភាសន៍ដើម្បីប្រមូលទិន្នន័យចងក្រងកិច្ចការស្រាវជ្រាវនេះ។

សូមជូនពរឲ្យលោកអ្នកមានគុណទាំងអស់ បានជួបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១៤ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា ២០២០-២០២១ បានធ្វើការស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់ទៅលើធនាគារ ABA ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមក។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការរៀបចំសៀវភៅនេះឡើង យើងខ្ញុំបានខិតខំស្រាវជ្រាវតាមរយៈការសម្ភាសន៍បុគ្គលិកនៅក្នុងធនាគារ ABA ព្រមទាំងមានការជួយជ្រោមជ្រែងពន្យល់ ណែនាំ និងការផ្តល់យោបល់ល្អៗរបស់សាស្ត្រាចារ្យដឹកនាំ។

ប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារABA" នេះគឺជាគំនិតស្លួចស្តើងមួយដែលលេចឡើងជារូបរាងដោយសារការខិតខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំ ដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវនេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះជាយ៉ាងណាយើងសង្ឃឹមថា និស្សិតនិងមិត្តអ្នកអានទាំងអស់ពិតជាមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា។

# មាតិកា

## សេចក្តីផ្តើម

**ទំព័រ**

១. លំនាំបញ្ហា ........................................ ១
២. ចំណោទបញ្ហា ........................................ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ២
៤. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ២
    ៤.១.ទិន្នន័យបន្ទាប់បន្សំ ........................................ ២
    ៤.២.ការវិភាគទិន្នន័យ ........................................ ៣
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៤

## ជំពូកទី១

## ការសិក្សាលើផ្នែកទ្រឹស្តី

១.១.ស្ថានភាពទូទៅរបស់ធនាគារពាណិជ្ជ ........................................ ៥
    ១.១.១.ប្រវត្តិនៃការកកើតធនាគារ ........................................ ៥
    ១.១.២.និយមន័យធនាគារ ........................................ ៦
១.២.លក្ខណៈទូទៅនៃឥណទាន ........................................ ៦
    ១.២.១.និយមន័យ ........................................ ៦
    ១.២.២.សមាសភាពនៃដំណើរការឥណទាន ........................................ ៧
    ១.២.៣.មុខងារឥណទាន ........................................ ៧
    ១.២.៤.ប្រភេទឥណទាន ........................................ ៨
        ១.២.៤.១.ឥណទានទោល ........................................ ៨
        ១.២.៤.២.ឥណទានក្រុម ........................................ ៨
១.៣.អត្ថប្រយោជន៍ឥណទាន ........................................ ៩
    ១.៣.១.អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់ ........................................ ៩
    ១.៣.២.អត្ថប្រយោជន៍ចំពោះអាជីវកម្ម ........................................ ៩
    ១.៣.៣.អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច ........................................ ១០
១.៤.គ្រោះថ្នាក់នៃការប្រើប្រាស់ឥណទានខុសគោលដៅ ........................................ ១០

១.៤.១.គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់ ........ ១០
១.៤.២.គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម........ ១១
១.៥.លក្ខណៈទូទៅនៃនីតិវិធីក្នុងការផ្តល់ឥណទាន ........ ១១
១.៥.១.និយមន័យ........ ១១
១.៥.២.នីតិវិធីក្នុងការផ្តល់ឥណទាន ........ ១១
១.៥.៣.គោលការណ៍នៃការផ្តល់ឥណទាន ........ ១៧
១.៥.៣.១.គោលការណ៍នៃការផ្តល់ឥណទានមានគោលដៅ និងផែនការ ........ ១៧
១.៥.៣.២.គោលការណ៍នៃការផ្តល់ឥណទានដោយសងវិញទាំងដើមទាំងការ ........ ១៧
១.៥.៣.៣.គោលការណ៍ផ្តល់ឥណទានដោយមានការធានា ........ ១៧
១.៥.៣.៤.គោលការណ៍នៃការប្រមូលប្រាក់បំណុល ........ ១៨
១.៥.៣.៥.គោលការណ៍ផាកពិន័យចំពោះការសងបំណុលយឺតយ៉ាវ
និងការខកខានមិនបានសង ........ ១៩
១.៥.៤.ការវាយតម្លៃឥណទាន ........ ១៩
១.៦.វិធីសាស្រ្តសងរំលស់នៃឥណទាន........ ១៩
១.៦.១.បំណុលដែលសងតែម្តងគត់នៅកាលអវសាន........ ១៩
១.៦.២.បំណុលសងតែការប្រាក់........ ១៩
១.៦.៣.បំណុលសងរំលស់ ........ ២០
១.៧.ការគ្រប់គ្រងហានិភ័យឥណទាន ........ ២០
១.៧.១.និយមន័យ ........ ២០
១.៧.២.មូលហេតុដែលបណ្តាលឲ្យមានហានិភ័យ........ ២០
១.៧.២.១.មូលហេតុបណ្តាលមកពីអតិថិជន........ ២០
១.៧.២.២.មូលហេតុបណ្តាលមកពីធនាគារ........ ២១
១.៧.២.៣.មូលហេតុដែលបណ្តាលមកពីសេដ្ឋកិច្ច សង្គម និង គ្រោះធម្មជាតិ........ ២១
១.៧.៣.ផលប៉ះពាល់ដែលបណ្តាលឲ្យមានហានិភ័យឥណទាន........ ២១
១.៧.៤.យុទ្ធសាស្រ្តក្នុងការកាត់បន្ថយហានិភ័យឥណទាន........ ២២
១.៨.វិធីសាស្រ្តគិតការប្រាក់ ........ ២៣
១.៨.១.និយមន័យ........ ២៣
១.៨.២.ការប្រាក់ធម្មតា........ ២៣
១.៨.៣.ការប្រាក់ផ្គួប ........ ២៣
១.៩.វិធីសាស្រ្តដោះស្រាយឥណទានមានបញ្ហា ........ ២៤

១.១០.តួនាទីឥណទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ..... ២៥

## ជំពូកទី២

## ស្ថានភាពទូទៅ

២.១.ប្រវត្តិសង្ខេប ..... ២៦
២.១.១.ប្រវត្តិសង្ខេបរបស់ធនាគារ ABA ..... ២៦
២.១.២.ប្រវត្តិសង្ខេបរបស់ធនាគារ ABA សាខាខេត្តពោធិ៍សាត់ ..... ២៧
២.២.អត្តសញ្ញាណរបស់ធនាគារ ABA ..... ២៧
២.២.១.ស្លាកសញ្ញា ..... ២៧
២.២.២.អត្ថន័យនិមិត្តសញ្ញា ..... ២៨
២.៣.ទីតាំងរបស់ធនាគារ ABA សាខាខេត្តពោធិ៍សាត់ ..... ២៨
២.៤.ភាគទុនិក និងដៃគូ ..... ២៨
២.៤.១.ភាគទុនិក ..... ២៨
២.៤.២.ដៃគូ ..... ២៩
២.៥.ទស្សនៈវិស័យ បេសកម្ម និងគុណតម្លៃរបស់ធនាគារ ABA ..... ២៩
២.៥.១.ទស្សនៈវិស័យ ..... ២៩
២.៥.២.បេសកម្ម ..... ៣០
២.៥.៣.គុណតម្លៃ ..... ៣០
២.៦.ផលិតផល និងសេវាកម្មរបស់ធនាគារ ABA ..... ៣១
២.៦.១.សេវាប្រាក់កម្ចី ..... ៣១
២.៦.២.សេវាកម្មផ្ទេរប្រាក់ ..... ៣១
២.៦.៣.សេវាស្វ័យធនាគារ ..... ៣២
២.៦.៤.សេវាទូទាត់អនឡាញ PayWay ..... ៣៤
២.៦.៥.សេវាបើកប្រាក់បៀវត្ស ..... ៣៤
២.៦.៦.កាតទូទាត់ ..... ៣៤

## ជំពូកទី៣

## ការគ្រប់គ្រងឥណទានគេហដ្ឋាន

៣.១.លក្ខណៈទូទៅនៃឥណទានគេហដ្ឋាន ..... ៣៥
៣.១.១.និយមន័យ ..... ៣៥
៣.១.២.គោលបំណង ..... ៣៥

៣.១.៣.អត្ថប្រយោជន៍ ........ ៣៥

៣.១.៣.១.សម្រាប់ធនាគារ ........ ៣៥

៣.១.៣.២.សម្រាប់អតិថិជន ........ ៣៥

៣.១.៣.៣.សម្រាប់សង្គម ........ ៣៥

៣.១.៤.ទីផ្សារគោលដៅ ........ ៣៥

៣.១.៥.ផលិតផលឥណទានគេហដ្ឋាន ........ ៣៦

៣.១.៥.១.ទំហំនៃការផ្តល់ឥណទាន ........ ៣៦

៣.១.៥.២.រយៈពេលផ្តល់ឥណទាន ........ ៣៦

៣.១.៥.៣.អត្រាការប្រាក់ ........ ៣៦

៣.១.៥.៤.វិធីសាស្ត្រនៃការសងត្រឡប់មកវិញ ........ ៣៦

៣.២.លក្ខខណ្ឌតម្រូវសម្រាប់ឥណទានគេហដ្ឋាន ........ ៣៩

៣.២.១.លក្ខខណ្ឌសម្រាប់អ្នកខ្ចី ........ ៣៩

៣.២.២.ការលើកលែង/ព្រំដែនក្នុងការផ្តល់ឥណទាន ........ ៣៩

៣.២.៣.ទ្រព្យធានា ........ ៣៩

៣.២.៤.អ្នកធានា ........ ៤០

៣.២.៥.ការរៀបចំឯកសារ ........ ៤០

៣.២.៦.ការខកខានសង និងការផាកពិន័យ ........ ៤០

៣.២.៦.១.ការខកខានសង ........ ៤១

៣.២.៦.២.ការផាកពិន័យ ........ ៤១

៣.២.៦.៣.ការផាកពិន័យចំពោះការបង់ផ្តាច់មុនកាលកំណត់ ........ ៤១

៣.៣.នីតិវិធីក្នុងការផ្តល់ឥណទានគេហដ្ឋាន ........ ៤១

៣.៤.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ........ ៤៥

៣.៤.១.ការធ្វើចំណាត់ថ្នាក់ឥណទាន ........ ៤៥

៣.៤.១.១.និយមន័យ ........ ៤៥

៣.៤.១.២.ប្រភេទនៃចំណាត់ថ្នាក់ឥណទាន ........ ៤៦

៣.៤.២.ការធ្វើសំវិធានធន ........ ៤៦

៣.៤.២.១.ការធ្វើសំវិធានធនទូទៅ ........ ៤៦

៣.៤.២.២.ការធ្វើសំវិធានធនជាក់លាក់ ........ ៤៧

៣.៥.ការគ្រប់គ្រងហានិភ័យឥណទានគេហដ្ឋាន ........ ៤៧

៣.៥.១.និយមន័យហានិភ័យឥណទាន ........ ៤៧

៣.៥.២.មូលហេតុនៃហានិភ័យឥណទាន ..... ៤៧
៣.៥.៣.វិធីសាស្រ្តកាត់បន្ថយហានិភ័យឥណទាន ..... ៤៨
៣.៥.៤.វិធីសាស្រ្តដោះស្រាយបញ្ហាឥណទានគេហដ្ឋាន ..... ៤៩
៣.៦.ការវិភាគSWOT ..... ៥០
៣.៦.១.ចំណុចខ្លាំង ..... ៥០
៣.៦.២.ចំណុចខ្សោយ ..... ៥១
៣.៦.៣.ឱកាស ..... ៥១
៣.៦.៤.ការគំរាមកំហែង ..... ៥១
**សេចក្តីសន្និដ្ឋាន** ..... ៥២
**ការផ្តល់អនុសាសន៍** ..... ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

ABA = Advanced Bank of Asia Limited

ATM = Automatic Teller Machine

CVD = Cash Disbursement Voucher

FV = Future Value

IME = Independent Medical Examination

PV = Present Value

SWIFT = Society for Worldwide Interbank Financial Telecommunication

SWOT = Strength, Weakness, Opportunity, Threat

## បញ្ជីតារាង

- តារាងទី១: របៀបសងបង់រំលស់ប្រចាំខែទាំងដើមទាំងការស្មើៗគ្នា ........................................ ៣៧
- តារាងទី២: របៀបសងបង់រំលស់ប្រចាំខែជាមួយប្រាក់ដើមថេរ ............................................. ៣៨

## បញ្ជីរូបភាព

- ស្លាកសញ្ញារបស់ធនាគារ ABA ........................................................................................ ២៧

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជានាពេលបច្ចុប្បន្នមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដោយបានធ្វើកំណែទម្រង់សេដ្ឋកិច្ច សង្គម និងហិរញ្ញវត្ថុ ដែលបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅដល់គោលដៅនៃការពង្រឹងយន្តការទីផ្សារ និងធានាអោយបាននូវនិរន្តន៍ភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងបែងចែកនូវលទ្ធផលជោគជ័យនៃសេដ្ឋកិច្ចប្រកបដោយសមធម៌ ដើម្បីឆ្ពោះទៅរកការលុបបំបាត់ភាពក្រីក្រដល់ប្រជាពលរដ្ឋកម្ពុជា។ ដោយសារសក្តានុពលសេដ្ឋកិច្ច រួមទាំងគោលនយោបាយរបស់រដ្ឋាភិបាលបែបនេះ ទើបបង្កឲ្យមានភាពងាយស្រួលដល់អ្នកវិនិយោគក្នុងស្រុក និងក្រៅស្រុកបង្កើតអាជីវកម្ម។ ជាពិសេសប្រភេទអាជីវកម្មសម្រាប់សហគ្រាសខ្នាតមធ្យម ដែលបានដើរតួនាទីយ៉ាងសកម្ម ក្នុងការជួយដល់កំណើនសេដ្ឋកិច្ច។ ជាក់ស្តែង សហគ្រាសប្រភេទនេះមានការកើនឡើងច្រើន។ ដូច្នេះហើយទើបធ្វើអោយតម្រូវការខាងផ្នែកហិរញ្ញវត្ថុមានការកើនឡើងយ៉ាងឆាប់រហ័ស ស្របពេលដែលអាជីវកម្មទាំងនេះមានការផុសផុលឡើងជាលំដាប់ក្នុងប្រទេស។ ជាមួយគ្នានេះដែរដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុជាច្រើនបែបនេះ ទើបជំរុញឲ្យស្ថាប័នធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាលដ៏ច្រើនសន្ធឹកសន្ធាប់បានដើរតួជាអ្នកផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ ដូចជាការផ្តល់ឥណទានសម្រាប់វិនិយោគិន ដែលមានតម្រូវការដូចជាខ្វះធនធាននិងពង្រីកអាជីវកម្មជាដើម។ ទន្ទឹមនឹងនេះទោះបីវិស័យធនាគារមានការលូតលាស់យ៉ាងឆាប់រហ័ស ក៏ជានិច្ចកាលប្រទេសកម្ពុជានៅតែមានតម្រូវការផ្នែកហិរញ្ញវត្ថុដែរ ពីព្រោះតែវិស័យនេះដើរតួយ៉ាងសំខាន់ក្នុងការបង្កើត ពង្រីកអាជីវកម្ម និងផលិតផលក្នុងការបង្កើតចំណូលសម្រាប់លើកកម្ពស់កម្រិតជីវភាពក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងកសិកម្មតាមរយៈការផ្តល់ជាឥណទានសម្រាប់អ្នកដែលមានតម្រូវការខាងផ្នែកហិរញ្ញវត្ថុ។

ដោយមានការរីកចម្រើនទៅលើវិស័យហិរញ្ញវត្ថុបែបនេះ ទើបបណ្តាលឲ្យស្ថាប័នធនាគារកំពុងតែមានការរីកដុះដាលគួរឲ្យកត់សម្គាល់។ ហេតុនេះហើយធនាគារទាំងអស់នោះ បានព្យាយាមពង្រឹងសមត្ថភាពរបស់ខ្លួនតាមរយៈការបង្កើតនូវប្រភេទផលិតផល និងសេវាកម្មថ្មីៗ ជាច្រើនដើម្បីបំពេញតម្រូវការរបស់សង្គមនាពេលដែលមានកំណើនសេដ្ឋកិច្ចក្នុងវិស័យនេះ។ ក្នុងនោះដែរធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ ហៅកាត់ថា ABA ក៏បានផ្តល់សេវាឥណទាន ជូនសាធារណៈជនដែលមានតម្រូវការផ្នែកហិរញ្ញវត្ថុ ដើម្បីយកទៅបំពេញចំនុចខ្វះខាតក្នុងជីវភាពប្រចាំថ្ងៃ និងអាជីវកម្មរបស់ពួកគាត់។

ក្នុងចំណោមសេវាកម្មទាំងនោះ "ឥណទានគេហដ្ឋាន" ជាប្រភេទឥណទានមួយដែរកំពុងមានការចាប់អារម្មណ៍ និងផ្តល់នូវអត្ថប្រយោជន៏ជាច្រើនសម្រាប់តម្រូវការបច្ចុប្បន្ន។ ហេតុដូចនេះហើយ ទើបមានការសិក្សា

ស្រាវជ្រាវប្រធានបទនៃការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ABA ត្រូវបានយកមកសិក្សាស៊ីជម្រៅ អំពីគោលការណ៍ និងដំណើរការ។

## ២. ចំណោទបញ្ហា

ឥណទានមានសារៈសំខាន់ណាស់នាពេលបច្ចុប្បន្ននេះ ជាពិសេសឥណទានគេហដ្ឋានដើរតួនាទីជំរុញអោយប្រជាពលរដ្ឋមានលំនៅដ្ឋានសមរម្យដែលជាជម្រើសដំបូងគេក្នុងជីវិតរស់នៅប្រកបដោយសុភមង្គល។

- តើធនាគារ ABA មានគោលការណ៍យ៉ាងដូចម្តេចខ្លះចំពោះការផ្តល់ឥណទានគេហដ្ឋានដល់អតិថិជនរបស់ខ្លួន?
- តើនីតិវិធីបែបណាដែលធនាគារ ABA យកមកប្រើប្រាស់ក្នុងការផ្តល់ឥណទានគេហដ្ឋាន?
- តើការផ្តល់ឥណទានគេហដ្ឋាន ដល់អតិថិជនមានប៉ុន្មានដំណាក់កាល?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃការសិក្សាស្រាវជ្រាវគឺផ្តោតសំខាន់លើការគ្រប់គ្រងឥណទានគេហដ្ឋាន ក្នុងនោះមានគោលបំណងជាក់លាក់មួយចំនួនដូចខាងក្រោម៖

- ការសិក្សាស្ថានភាពទូទៅរបស់ធនាគារ ABA
- ការសិក្សាពីគោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានគេហដ្ឋាន
- ការសិក្សាពីការត្រួតពិនិត្យ និងការតាមដានឥណទាន
- សិក្សាពីការខកខានមិនបានសង និងការផាកពិន័យ
- សិក្សាពីនីតិវិធីក្នុងការដោះស្រាយឥណទានមានបញ្ហា
- សិក្សាពីប្រសិទ្ធភាព និងចំណុចខ្វះខាតនៃការផ្តល់ឥណទាន
- សិក្សាពីចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រងឥណទានគេហដ្ឋាន របស់ធនាគារ ABA
- ធ្វើការសន្និដ្ឋាន និងការផ្តល់អនុសាសន៏ក្នុងការកែលម្អការគ្រប់គ្រងអោយមានប្រសិទ្ធភាពខ្ពស់។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើការគ្រប់គ្រងឥណទានគេហដ្ឋានត្រូវពឹងផ្អែកលើប្រភពទិន្នន័យ និងការវិភាគទិន្នន័យ ដូចខាងក្រោម៖

### ៤.១.ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យនេះជាទិន្នន័យដែលមានស្រាប់របស់ធនាគារដែលបានផ្សព្វផ្សាយ និងរក្សាទុក ដូចនេះការសិក្សាត្រូវប្រមូលទិន្នន័យបែបនេះរួមមាន៖

- ពីធនាគារស្តីពីឥណទានគេហដ្ឋាន និងព័ត៌មានផ្សេងៗ

- ឯកសារស្តីពីឥណទាននៅក្នុងបណ្ណាល័យ
- តាមរយៈអ៊ីនធឺណេត និង គេហទំព័ររបស់ធនាគារ។
- ឯកសារដែលដកស្រង់ពីរបាយការណ៍របស់និស្សិតបញ្ចប់ការសិក្សាឆ្នាំមុនៗ

**៤.២.ការវិភាគទិន្នន័យ**

- បន្ទាប់ពីប្រមូលបានព័ត៌មាន និងទិន្នន័យរួមមក ការសិក្សាស្រាវជ្រាវលើប្រធានបទនេះនឹងធ្វើការបកស្រាយនូវទិន្នន័យតាមបែបគុណវិស័យ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារធនាគារ ABA មានសេវាឥណទានច្រើនប្រភេទដែលកំពុងផ្តល់ជូនដល់ពលរដ្ឋគ្រប់ប្រភេទ និងគ្រប់ប្រភេទអាជីវកម្ម ដូចនេះការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់លើទំហំនិងដែនកំណត់ដូចខាងក្រោម៖

**ក. ទំហំ**

ការសិក្សានេះគឺសិក្សាទៅលើធនាគារ ABA សាខាខេត្តពោធិ៍សាត់តែប៉ុណ្ណោះ

**ខ. ដែនកំណត់**

ការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើការគ្រប់គ្រងឥណទានគេហដ្ឋានជាមួយទិន្នន័យឆ្នាំ២០១៩

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទនេះវាផ្តល់សារៈប្រយោជន៍ដូចជា៖

❖ **ចំពោះខ្លួនឯង**

- ទទួលបានចំណេះដឹងបន្ថែមក្នុងផ្នែកធនាគារ
- ទទួលបានបទពិសោធខាងធនាគារដើម្បីយកទៅអនុវត្តន៍
- ទទួលបានចំណេះដឹងបន្ថែមអំពីការគ្រប់គ្រង
- បំពេញលក្ខខណ្ឌដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច។

❖ **ចំពោះធនាគារ**

- ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ឲ្យធនាគារនូវការអភិវឌ្ឍន៍ប្រព័ន្ធនៃការគ្រប់គ្រងឥណទានធនាគារឲ្យកាន់តែមានប្រសិទ្ធភាព
- បង្ហាញឲ្យដឹងពីភាពខ្លាំងនិងភាពខ្សោយដើម្បីយកទៅកែច្នៃនិងពង្រឹងបន្ថែម។

❖ **ចំពោះសារធារណៈជន**

- ទទួលបានចំណេះដឹងពីគោលការណ៍និងនីតិវិធីការផ្តល់ឥណទាននៅក្នុងធនាគារ
- ផ្តល់គំនិត ចំណេះដឹងថ្មីក្នុងការការរិះរកវិធី និងយុទ្ធសាស្ត្រនៃការគ្រប់គ្រងឥណទាន

- បង្ហាញឲ្យដឹងពីភាពខ្លាំង និងភាពខ្សោយនៃការផ្តល់ឥណទានរបស់ធនាគារដើម្បីឲ្យមានការប្រុងប្រយ័ត្ន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ABA សាខាខេត្តពោធិសាត់។

**រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ**



# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១.លក្ខណៈទូទៅរបស់ធនាគារពាណិជ្ជ

### ១.១.១.ប្រវត្តិនៃការកកើតធនាគារ[1]

ការកកើតនៃធនាគារ គឺបានផ្សារភ្ជាប់ទៅនឹងប្រវត្តិនៃការរីកចម្រើនរបស់វិស័យផលិតកម្ម។ ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចគឺជាលក្ខខណ្ឌ និងការទាមទារនូវការអភិវឌ្ឍរបស់ធនាគារនីមួយៗ។ រហូតមកដល់បច្ចុប្បន្ននេះ ការអភិវឌ្ឍប្រព័ន្ធធនាគារបានជំរុញឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចទាំងមូល។

ធនាគារចាប់ផ្ដើមកើតឡើងតាមរយៈមុខងារប្ដូរប្រាក់របស់ជាងមាស។ ចំពោះការចរាចរលុយនៅក្នុងប្រទេស និងនៅក្នុងតំបន់នីមួយៗ ជាពិសេសចំពោះពាណិជ្ជកម្មអន្តរជាតិទាមទារឲ្យមានការផ្លាស់ប្ដូរប្រាក់តាមច្រកព្រំដែនដើម្បីងាយស្រួលក្នុងការទិញ និងលក់ទំនិញ (ការដោះដូរ)។ ដូច្នោះទាមទារឲ្យមានការបង្កើតហាងប្ដូរប្រាក់ ដើម្បីងាយស្រួលធ្វើការដោះដូរនូវរូបិយប័ណ្ណរបស់ប្រទេសនីមួយៗ។ ចំពោះអ្នករកស៊ីប្ដូរប្រាក់នេះភាគច្រើនជាអ្នកមាន និងពីមុនអាចជាអ្នកផ្ដល់កម្ចីដោយយកការប្រាក់ខ្ពស់ ឬរក្សាទុកលុយឲ្យអ្នកធ្វើអាជីវកម្មផ្សេងៗដែលត្រូវការដើមទុន។ ដូចនេះហើយ អ្នករកស៊ីប្ដូរប្រាក់បានបង្កើតមុខងារថ្មីមួយទៀត គឺរក្សាលុយទុក។ ពួកគេកាន់តែមានចំណូលច្រើនបន្ថែម ម៉្យាងទៀតការរក្សាទុកលុយនេះកាន់តែច្រើនឡើងៗ ជាហេតុធ្វើឲ្យមានការទូទាត់ថ្លៃទំនិញជំនួសវិញ ឬការទូទាត់មិនប្រើសាច់ប្រាក់។ តាមរយៈការទូទាត់មិនប្រើសាច់ប្រាក់នេះ បានធ្វើឲ្យពាណិជ្ជករនាំគ្នាផ្ញើរប្រាក់កាន់តែច្រើនថែមទៀត។

ដំបូងបណ្ដាធនាគារនេះបានប្រើប្រាស់មូលដ្ឋានផ្ទាល់របស់ខ្លួនក្នុងការធ្វើប្រតិបត្តិការ។ ប៉ុន្តែកត្តានេះមិនអាចស្ថិតស្ថេរបានយូរអង្វែងទេ ម្ចាស់ធនាគារសង្កេតឃើញថា ជានិច្ចកាលមានអ្នកមកផ្ញើរលុយ និងអ្នកមកសុំខ្ចីលុយ ហើយអ្នកផ្ញើរលុយទាំងអស់នោះមិនបានដកប្រាក់ព្រមគ្នានោះទេ ជាហេតុធ្វើឲ្យបរិមាណលុយនៅសល់ច្រើននៅក្នុងធនាគារ។ ម្ចាស់ធនាគារក៏បានប្រើប្រាស់លុយដែលនៅសល់ទាំងនោះសម្រាប់ផ្ដល់ជាកម្ចី បន្ថែមដើម្បីបង្កើនប្រាក់ចំណេញ ហើយបានជំរុញឲ្យស្វែងរកយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ដើម្បីទាក់ទាញអ្នកមានលុយច្រើនយកមកដាក់បញ្ញើឲ្យកាន់តែច្រើនជាងមុន។ នៅក្នុងនោះដែរ មានម្ចាស់ធនាគារធំៗមួយចំនួនបានពង្រីកការផ្ដល់កម្ចីដល់ស្ដេចក្នុងគោលបំណងជាជំនួយក្នុងការធ្វើសឹកសង្គ្រាមផ្សេងៗ។ ជាងនេះទៅទៀតធនាគារបានផ្ដល់កម្ចីលើសពីប្រាក់បញ្ញើដែលខ្លួនមាន តែការធ្វើបែបនេះមានហានិភ័យខ្ពស់សម្រាប់ធនាគារ ដោយសារប្រាក់ចំណេញពីការផ្ដល់កម្ចីមានកម្រិតខ្ពស់បានធ្វើឲម្ចាស់ធនាគារជាច្រើនប្រើប្រាស់នូវលិខិតដែលបញ្ជាក់ប្រាក់បញ្ញើ

[1] លោកសាស្ត្រាចារ្យសួន ចំរើន, ២០១២, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ៥

(ជំនួសឲ្យការចរាចរមាសឬប្រាក់) និងបោះពុម្ពលិខិតដើម្បីផ្តល់កម្ចី។ ស្ថានភាពទាំងនេះបានធ្វើឲ្យធនាគារជាច្រើនគ្មានលទ្ធភាពសងបំណុល និងបានក្ស័យធនទៀតផង។

ការក្ស័យធនរបស់ធនាគារទាំងនោះបានធ្វើឲ្យការទូទាត់ត្រូវជួបវិបត្តិ និង ជះឥទ្ធិពលអាក្រក់ដល់អ្នកធ្វើអាជីវកម្ម ម៉្យាងវិញទៀតអត្រាការប្រាក់ខ្ពស់ធ្វើឲគេមិនអាចទទួលយកបាន។ ដូចនេះពួកគេក៏បានបង្កើតធនាគារដោយខ្លួនឯងដែលហៅថា ធនាគារពាណិជ្ជ។ ធនាគារពាណិជ្ជបានបង្កើតឡើងដោយក្រុមពាណិជ្ជករ ហើយក៏បានអនុវត្តន៍មុខងារដូចធនាគារមុនៗដែរ គឺទទួលបានប្រាក់បញ្ញើរក្សាទុក ទូទាត់ជំនួស និងផ្តល់ប្រាក់កម្ចី។ ដើម្បីទប់ស្កាត់នូវហានិភ័យមិនឲ្យកើតឡើង ធនាគារបានផ្តល់តែកម្ចីរយៈពេលខ្លីតែប៉ុណ្ណោះ រីឯសម្រាប់អ្នកប្រើប្រាស់ និងរដ្ឋាភិបាល ក៏មិនត្រូវបានអនុញ្ញាតដែរ។

តាមរយៈការរីកចម្រើននៃសេដ្ឋកិច្ច និងបច្ចេកទេសនេះដែរ ក៏បានធ្វើឲ្យប្រតិបត្តិការរបស់ធនាគារកាន់តែមានការរីកចម្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ គឺតាំងពីធនាគារលក្ខណៈបុគ្គលរហូតដល់បង្កើតធនាគារបែបក្រុមហ៊ុន។ លុះក្រោយមកទៀត មានធនាគារពាណិជ្ជចាប់មានការផ្តល់កម្ចីរយៈពេលវែង កម្ចីអ្នកប្រើប្រាស់ អ្នកទិញប័ណ្ណភាគហ៊ុន និងបង្កើតឡើងឲ្យមាននូវប្រភេទប្រាក់បញ្ញើជាច្រើនទៅតាមតម្រូវការរបស់អតិថិជន។

#### ១.១.២.និយមន័យធនាគារ

ធនាគារត្រូវបានគេឲ្យឈ្មោះថា ជាអន្តរការីហិរញ្ញវត្ថុរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច ហើយត្រូវបានមនុស្សជាច្រើនហៅធនាគារថា ស្ថាប័នទទួលប្រាក់បញ្ញើ (Depository Institutions) ដែលមានទទួលប្រាក់បញ្ញើពីអ្នកសន្សំ ហើយបង្កើតបានជាប្រាក់កម្ចីផ្តល់ឲអ្នកដែលត្រូវការប្រាក់។[2]

ធនាគារ គឺជាអន្តរការីហិរញ្ញវត្ថុដែលទទួលយកប្រាក់បញ្ញើ និងប្រើប្រាស់ប្រាក់បញ្ញើទាំងនោះជាប្រាក់ឥណទានដោយផ្ទាល់ ឬឆ្លងកាត់ទីផ្សារមូលធន។ ធនាគារបានភ្ជាប់អតិថិជនដែលមានឱនភាពមូលធន (កង្វះខាតប្រាក់) ទៅឲ្យអតិថិជនដែលមានអតិរេកមូលធន (សល់ប្រាក់)។[3]

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុដែលបម្រើសេវាកម្មធំទូលាយជាងស្ថាប័នហិរញ្ញវត្ថុដទៃទៀត ឬជាអង្គភាពដែលស្វែងរកប្រាក់ចំណេញមានទ្រព្យសកម្ម និងបំណុលច្រើន។ [4]

### ១.២.លក្ខណៈទូទៅនៃឥណទាន

#### ១.២.១.និយមន័យ

---

[2] ម៉ៅ ស្រីអូន និងស៊ិន ស៊ីណុច, ២០១៩, " សេវាប្រាក់បញ្ញើ-សន្សំ ", ទំព័រ ៦

[3] ម៉ៅ ស្រីអូន និងស៊ិន ស៊ីណុច, ២០១៩, " សេវាប្រាក់បញ្ញើ-សន្សំ ", ទំព័រ ៦

[4] លោកសាស្ត្រាចារ្យ ងួន ហេង, គ្មានកាលបរិច្ឆេទ, " រូបិយវត្ថុ និងធនាគារ ",ទំព័រ៧

**ឥណទាន** គឺជាការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់ជាបណ្ដោះអាសន្នទៅឲ្យអ្នកខ្ចីនូវបរិមាណតម្លៃមួយ អាចជាវត្ថុ ឬរូបិយវត្ថុ (លុយ) ជាមួយនឹងការសន្យាសងត្រឡប់វិញដល់ម្ចាស់ទាំងដើមនិងការប្រាក់។[5]

**ឥណទាន** គឺជាការឲ្យអតិថិជនខ្ចីប្រាក់ ដើម្បីបំពេញសេចក្ដីត្រូវការផ្សេងៗរបស់ពួកគេ ហើយអតិថិជនមានកាតព្វកិច្ចសងត្រឡប់មកវិញនូវប្រាក់ដើម និងការប្រាក់។[6]

### ១.២.២.សមាសភាពនៃដំណើរការឥណទាន

[7]មានកត្តាជាច្រើន គួរសម្រេចចិត្តដោយម្ចាស់បំណុល មុននឹងទទួលយកការសន្យារបស់អ្នកស្នើសុំដើម្បីសងបំណុលដោយប្រើឥណទានជំនួសសាច់ប្រាក់សុទ្ធ។ ក្នុងនោះគឺមានតែប្រតិបត្តិការឥណទានមួយគត់ ដែលអាចកំណត់ភារកិច្ចនេះបានហើយមានការពាក់ព័ន្ធនឹងការទទួលខុសត្រូវពីមន្ត្រីឥណទាន។

សមាសភាពនៃដំណើរការឥណទានមានដូចខាងក្រោម៖

_ ហានិភ័យ

_ ពេលវេលា

_ ការធានា ឬវត្ថុបញ្ចាំ

_ ការឯកភាពតាមច្បាប់

_ ចំណាយលើប្រតិបត្តិការ

_ អតិផរណា និងបន្ទុកហិរញ្ញវត្ថុ។

### ១.២.៣.មុខងារឥណទាន

ការផ្ដល់ឥណទានដល់សាធារណៈជន មានមុខងារប្លែកពីគ្នាទៅតាមប្រភេទនៃកម្ចី ឬ តម្រូវការរបស់អតិថិជន។ ខាងក្រោមនេះមានមុខងាររួមរបស់ឥណទាន ៖

- ផ្ដល់មូលនិធិឲ្យអ្នកខ្ចី ដើម្បីពង្រឹងមុខជំនាញ ឬ អាជីវកម្ម និងបង្កើតកម្រិតជីវភាពតាមចំណូលអនាគតដែលសង្ឃឹមទុក។

- ធ្វើឲ្យធនាគារទទួលប្រាក់ចំណេញតាមរយៈ ការប្រើប្រាស់ប្រភពមូលធនហិរញ្ញវត្ថុរបស់ខ្លួន និងការបង្កើតទ្រព្យសម្បត្តិភាពទុនិកដោយសារតែការកើនឡើងនូវប្រាក់ចំណេញ។

---

[5] លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ, ,២០២០, " ការគ្រប់គ្រងឥណទាន ",ទំព័រ១៧

[6] https://www.facebook.com/Khemsarithedu/

[7] ហុង ម៉ូលីកា និងសឿង សុខឃីម, ២០១៩, " ការគ្រប់គ្រងឥណទានខ្នាតតូច និងធម្យម ", ទំព័រ ១១

- ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការប្រមូលផ្តុំមូលធន និងដាក់ឲ្យមានការចរាចរក្នុងផលិតកម្មដល់សង្គមតាមរយៈការបង្កើតនូវទ្រព្យសម្បត្តិ បង្កើតការងារ និងជម្រុញឲ្យមាននិរន្តភាពអាជីវកម្ម ដើម្បីស្រូបយកផលប្រយោជន៍ពីប្រភពធនធានធម្មជាតិរបស់ប្រទេសខ្លួន។

- ផ្តល់មូលធនឲ្យអ្នកប្រើប្រាស់សម្រាប់ទិញ-លក់ទំនិញ ឬសេវាកម្ម។

- ផ្តល់មូលធនឲ្យអ្នកប្រើប្រាស់សម្រាប់ទិញឧបករណ៍ និងមធ្យោបាយអាជីវកម្មរបស់ខ្លួន។

- កាត់បន្ថយការរកស៊ីចងការប្រាក់ដែលមានការប្រាក់ខ្ពស់ហួសហេតុ។

- បង្កើតប្រសិទ្ធភាពនៃការប្រើប្រាស់ឥណទានតាមគ្រួសារ។

- ផ្លាស់ប្តូរផ្នត់គំនិតក្នុងការទទួលខុសត្រូវ និងការប្រឹងប្រែងសម្រាប់ជោគវាសនារបស់ខ្លួន។

- បង្កើតផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាឥណទាន។

**១.២.៤.ប្រភេទឥណទាន**[8]

ប្រតិបត្តិការឥណទាន កើតឡើងនៅក្នុងទម្រង់ច្រើនផ្សេងៗគ្នា។ ការធ្វើចំណាត់ថ្នាក់នៃប្រភេទឥណទានគឺអាស្រ័យលើគោលបំណងនៃការប្រើប្រាស់ឥណទាន និងវិធីសាស្ត្រក្នុងការសងត្រឡប់មកវិញ។ ឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគេបែងចែកជាពីរប្រភេទ គឺ ឥណទានទោល ( Individual Loan ) និងឥណទានក្រុម ( Group Loan )។

**១.២.៤.១.ឥណទានទោល** ( Individual Laon )

ឥណទានទោល ( Individual Laon ) គឺជាការផ្តល់ឥណទានជូនអតិថិជនជាឯកត្តជនដោយតម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមានការខកខានមិនបានសងបំណុល ។ ឥណទានប្រភេទនេះគឺផ្តល់សម្រាប់មុខជំនួញខ្នាតតូច និងមធ្យម។

**១.២.៤.២.ឥណទានក្រុម** ( Group Laon )

ឥណទានក្រុម ( Group Laon ) គឺជាឥណទានសម្រាប់ផ្តល់ជូនប្រជាកសិករក្រីក្រ ដែលមានមុខជំនាញឬកសិកម្មខ្នាតតូចតាច ដោយមិនតម្រូវឲ្យដាក់ទ្រព្យសម្បត្តិធានា ( តែគ្រឹះស្ថានខ្លះតម្រូវឲ្យមានទ្រព្យធានា ) ប៉ុន្តែអតិថិជនត្រូវបានចងគ្នាជាក្រុមពី បី ទៅបួននាក់។ ការចងគ្នាជាក្រុមបែបនេះគឺសម្រាប់ឲ្យសមាជិកក្នុងក្រុមធានាគ្នាទៅវិញទៅមក និងត្រូវចេញសងជួសគ្នា ប្រសិនបើសមាជិកណាម្នាក់ខកខានមិនបានសង។

[8] ម៉ៃ សុខជេដ្ឋា, ២០០៥, " ស្ថាប័នហិរញ្ញវត្ថុកម្ពុជា ", ទំព័រ ៤២

## ១.៣.អត្ថប្រយោជន៍ឥណទាន[៩]

### ១.៣.១.អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់

#### ក.ធ្វើឲ្យកើនឡើងនៅជីវភាពរស់នៅ

ជាទូទៅអ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ឥណទាន ពីព្រោះពួកគាត់អាចប្រើប្រាស់ចំណូលនៅពេលអនាគតរបស់ពួកគាត់ ដើម្បីធ្វើការទូទាត់លើទំនិញ និងសេវាដែលពួកគាត់មានតម្រូវការ។ ដូច្នេះពួកគាត់អាចបង្កើនកម្រិតជីវភាពនៃការរស់នៅរបស់ពួកគាត់នាពេលបច្ចុប្បន្ន។

#### ខ.ដោះស្រាយពេលមានអាសន្ន

អ្នកប្រើប្រាស់ តែងតែត្រូវការប្រើប្រាស់ឥណទានជាចាំបាច់នៅពេលដែលពួកគេជួបនូវភាពអាសន្ន ឬវិបត្តិផ្សេងៗ ដូចជា បញ្ហាជួសជុលរថយន្ត បញ្ហាចូលមន្ទីរពេទ្យ និងគ្រោះថ្នាក់ដែលកើតឡើងមានតម្រូវការចំណាយបន្ទាន់។ កម្មវិធីឥណទាន ផ្តល់ជូនអ្នកប្រើប្រាស់នូវមធ្យោបាយសម្រាប់ចំណាយលើភាពអាសន្នទាំងអស់នោះ ។

#### គ.បង្កលក្ខណៈងាយស្រួល

ឥណទានអាចបង្កលក្ខណៈងាយស្រួលផងដែរដល់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់អាចធ្វើដំណើរជុំវិញពិភពលោកដោយប្រើប័ណ្ណឥណទាន សម្រាប់ធ្វើការទូទាត់ថ្លៃប្រេង ថ្លៃឧស្ម័ន ថ្លៃសណ្ឋាគារ សំបុត្រយន្តហោះ និងវត្ថុអនុស្សាវរីយ៍ជាដើម។ ដូចនេះ តម្រូវការសាច់ប្រាក់ចំនួនច្រើនត្រូវបានកាត់បន្ថយ។ អ្នកធ្វើដំណើរមិនចាំបាច់មានលុយតាមខ្លួនក៏បានដែរ ប្រសិនបើប័ណ្ណឥណទានរបស់ពួកគេអាចប្រើប្រាស់បានគ្រប់គោលបំណងទាំងអស់។

### ១.៣.២.អត្ថប្រយោជន៍ចំពោះអាជីវកម្ម

#### ក. ជួយពង្រីកទីផ្សារ

អាជីវកម្មជាច្រើនពឹងផ្អែកលើឥណទាន ដើម្បីពង្រីកទីផ្សារ និងស្វែងរកអ្នកប្រើប្រាស់របស់ពួកគេ។ ប្រសិនបើពួកគេផ្តល់ឱកាសសម្រាប់អតិថិជនរបស់ពួកគេ នោះនឹងមានមនុស្សជាច្រើនអាចចូលមកទិញបាន។ អតិថិជនជាច្រើនខ្វះខាតសាច់ប្រាក់ដើម្បីចំណាយ ឬ ពួកគេចង់ជ្រើសរើសយកជម្រើសប្រើប្រាស់ឥណទានដែលពួកគេអាចសងត្រឡប់វិញនាពេលក្រោយ។

#### ខ. ទទួលបានការផ្គត់ផ្គង់សន្និធិ និងសម្ភារៈសម្រាប់លក់

អាជីវកម្មមួយចំនួនធំ គឺបានពឹងផ្អែកលើកម្មវិធីឥណទានដែលផ្តល់ដោយអ្នកផ្គត់ផ្គង់របស់ពួកគេដើម្បីទទួលបានការផ្គត់ផ្គង់សន្និធិ និងតម្រូវការសម្ភារៈផ្សេងៗ ដើម្បីបំពេញប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

[៩] ហុង ម៉ូលីកា និងសឿង សុខឃីម, ២០១៩, " ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ", ទំព័រ ១២

អាជីវកម្មអាចពង្រីកការផលិត និងសន្ទុធិទំនិញយ៉ាងច្រើន ប្រសិនបើពួកគេអាចទទួលបានការទិញដោយប្រើឥណទាន។

**គ. ការទទួលបានមូលនិធិហិរញ្ញវត្ថុ**

អាជីវកម្មជាច្រើនតែងតែមានតម្រូវការដើមទុនសម្រាប់ចាប់ផ្តើម ថែរក្សា និងពង្រីកនូវប្រតិបត្តិការរបស់ពួកគេរៀងៗខ្លួន។ ក្រុមហ៊ុន ឬសហគ្រាសជាច្រើនមានបទពិសោធន៍ លំហូរសាច់ប្រាក់មិនដូចគ្នា ដែលការចំណាយគឺត្រូវឲ្យមានមូលនិធិ ( សាច់ប្រាក់ ) មុនការកកើតមានការលក់ផលិតផល និងសេវាកម្ម ដូចជាការចំណាយទៅលើទីតាំងថ្មី បុគ្គលិកថ្មី និងការចំណាយលើផ្នែកទីផ្សារផ្សេងៗទៀត ដែលមិនអាចដំណើរការបាន ប្រសិនបើគ្មានការផ្តល់កម្ចីអាជីវកម្ម។

**១.៣.៣.អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច**

ក្នុងន័យនេះ ឥណទានគឺជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតបានជាចលនាសាច់ប្រាក់ និងជាផ្នែកនៃផលិតកម្មនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ ឥណទានតែងតែផ្តល់មធ្យោបាយដើម្បីសេរីភាពដល់កម្រិតសកម្មសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ ( អត្រាការប្រាក់ )ខុសៗគ្នា។

តួនាទីរបស់ឥណទានមានសារៈសំខាន់ជាពិសេសនៅក្នុងគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយសារពើពន្ធ ដែលមានឥទ្ធិពលលើការចំណាយ និងធ្វើការត្រួតពិនិត្យអត្រាការប្រាក់។ ជាទូទៅយើងហៅថា ឥទ្ធិពលម៉ាក្រូសេដ្ឋកិច្ច។

## ១.៤.គ្រោះថ្នាក់នៃការប្រើប្រាស់ឥណទានខុសគោលដៅ[10]

នៅក្នុងភាពជាក់ស្តែង ឥណទានអាចមានផលអាក្រក់នៅពេលដែលយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ ហើយវាក៏បានចោទជាបញ្ហាជាច្រើនសម្រាប់អាជីវកម្ម អ្នកប្រើប្រាស់ និងសហគមន៍ទាំងមូលផងដែរ។ ភាគីអ្នកប្រើប្រាស់ឥណទានទាំងអស់ត្រូវដឹងថា ឥណទានដែលកំពុងប្រើប្រាស់គឺសម្រាប់តែគោលបំណងផលិតភាពតែប៉ុណ្ណោះ និងត្រូវចេះបង្កើតការប្រុងប្រយ័ត្នជាមួយនឹងស្មារតីយកចិត្តទុកដាក់ខ្ពស់។

### ១.៤.១.គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់

អ្នកប្រើប្រាស់ អាចប្រើប្រាស់ឥណទានមិនបានពេញលក្ខណៈ និងទទួលមកវិញនូវបទពិសោធន៍មិនល្អ។ ដោយការប្រើប្រាស់ឥណទានមិនបានល្អ ធ្វើឲ្យអ្នកប្រើប្រាស់មួយចំនួនមានបញ្ហាជាយថាហេតុនិងធ្វើឲ្យបាត់បង់លទ្ធភាពទូទាត់បំណុល។ ឥណទានវាជាអន្ទាក់សម្រាប់អ្នកប្រើប្រាស់ដែលធ្វេសប្រហែស ហើយលទ្ធ

[10] អេង កែវពិសិដ្ឋ, ២០១២, " ការគ្រប់គ្រងឥណទាន ", ទំព័រ ៣២-៣៥

ផលចុងក្រោយ និងឈានដល់បាត់បង់ទ្រព្យសម្បត្តិ ការក្ស័យធន មហន្តរាយចំណងអាពាហ៍ពិពាហ៍ និងមានកម្រិត គុណភាពឥណទាន ធ្វើឲ្យគេបាត់បង់ឱកាសសន្សំដែលជាគោលដៅយ៉ាងសំខាន់។

### ១.៤.២.គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម

ការធ្វើជំនួញ គួរប្រុងប្រយ័ត្ននៅពេលប្រើ និងការបន្តប្រើប្រាស់ឥណទាន។ នៅពេលដែលមានអតិថិជនមួយចំនួនបានទិញទំនិញ និងសេវាកម្ម ដោយប្រើឥណទាន ហើយមិនបានសងតាមកិច្ចព្រមព្រៀង នោះអាជីវកម្មនឹងបាត់បង់ចំណូលជាច្រើន។ បញ្ហានេះគឺភាគច្រើនកើតចំពោះអាជីវកម្មខ្នាតតូច ហើយមូលហេតុចម្បងមួយក្នុងចំណោមមូលហេតុសំខាន់ គឺដោយសារសមត្ថភាពក្នុងការគ្រប់គ្រងនយោបាយឥណទានមិនបានល្អ។

ដូចនេះអាជីវកម្មត្រូវប្រាកដចិត្តថា អតិថិជនល្អទើបមានឱកាសប្រើប្រាស់កម្មវិធីឥណទាន។ ផ្នែកប្រមូលក៏ជាកត្តាមួយសំខាន់ផងដែរ គឺ ត្រូវធ្វើយ៉ាងណាឲ្យមានលំហូរសាច់ប្រាក់ជាវិជ្ជមានពីដំណើរការឥណទាន។ ចំណាយថ្លៃដើម និងការប្រមូលឥណទានត្រូវត្រួតពិនិត្យឲ្យបានច្បាស់លាស់ដើម្បីកុំឲ្យបាត់បង់ចំណូល។

## ១.៥.លក្ខណៈទូទៅនៃនីតិវិធីក្នុងការផ្តល់ឥណទាន

### ១.៥.១.និយមន័យ[11]

គោលបំណងនៃការផ្តល់ឥណទានគឺធ្វើយ៉ាងណាឲ្យកម្ចីនោះទទួលបានប្រាក់ចំណេញនិងមានហានិភ័យទាបបំផុត។ ដូចនេះ គេទាមទារឲ្យមន្ត្រីទទួលបន្ទុកផ្នែកឥណទានទាំងអស់ត្រូវទទួលបានភាពជោគជ័យនៅក្នុងអាជីវកម្មរបស់ខ្លួនផងដែរ។

### ១.៥.២.នីតិវិធីក្នុងការផ្តល់ឥណទាន[12]

នីតិវិធីក្នុងការផ្តល់ឥណទានមានដូចជា ៖

❖ ដំណាក់កាលទី១៖ ការទទួលស្វាគមន៍អតិថិជន។ ភ្នាក់ងារឥណទាន បេឡាករ ឬរដ្ឋបាល ត្រូវ៖

- អញ្ជើញអតិថិជនអង្គុយកន្លែងសមរម្យ ដែលពុំមានការរំខានពីមនុស្សដទៃទៀត
- សាកសួរពីគោលបំណងដែលគាត់ត្រូវការ
- ពន្យល់ពីក្រុមហ៊ុន ពីឥណទាន និងវិធីសងត្រឡប់មកវិញ
- សាកសួរពីប្រវត្តិ និងមុខរបរអតិថិជន
- ប្រាប់អតិថិជនពីតម្រូវការឯកសារ ID

---

[11] រុន សិរីមាលា និងសុខ ថានីន, ២០១១, " ការផ្តល់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច ", ទំព័រ ២១

[12] លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ,២០១៩, " ការគ្រប់គ្រងឥណទាន "ទំព័រ ១៨

ចំពោះអតិថិជនដែលមានលក្ខណៈអាចផ្តល់ឥណទានបាន យើងត្រូវបន្តដល់ដំណាក់កាលទី២។

- ❖ ដំណាក់កាលទី២៖ ការបំពេញពាក្យស្នើសុំឥណទាន។
- រៀបចំបំពេញពាក្យជូនអតិថិជន ( បំពេញចូលទម្រង់ទាំងអស់ )
- ថតចម្លងអត្តសញ្ញាណប័ណ្ណនិងឯកសារផ្សេងៗ
- ទំនាក់ទំនងសួរភ្នាក់ងារឥណទានក្នុងការកំណត់ជួបអតិថិជន
- កំណត់ពេលវេលាជាមួយអតិថិជនក្នុងការជួបដល់លំនៅដ្ឋាន ទីកន្លែងប្រកបអាជីវកម្មដែលភ្នាក់ងារឥណទានចាំបាច់ចុះត្រួតពិនិត្យ

អ្នកទទួលពាក្យ ត្រូវថ្លែងអំណរគុណដល់អតិថិជនពីការផ្តល់សេវាកម្ម រួចបញ្ជូនពាក្យដែលបានបំពេញរួចដល់ភ្នាក់ងារឥណទានដែលទទួលខុសត្រូវផ្នែកប្រតិបត្តិការ។

- ❖ ដំណាក់កាលទី៣៖ ការចុះអង្កេត និងវាយតម្លៃអតិថិជន។ ភ្នាក់ងារឥណទានចុះសាកសួរអ្នករស់នៅជិតខាងអតិថិជន ដោយមិនបង្ហាញពីគោលបំណង ឬសមាសភាពពិតប្រាកដក្នុងគោលបំណងទទួលបានព័ត៌មានពិតពីអតិថិជន។ បន្ទាប់មកភ្នាក់ងារឥណទាន ត្រូវ ៖
- ជួបអតិថិជនតាមការណាត់
- ពិនិត្យសកម្មភាពមុខរបរ និងទ្រព្យសម្បត្តិដាក់បញ្ចាំរបស់អតិថិជន
- ធ្វើគំរោងជំនួញតាមសភាពជាក់ស្តែងនៃមុខរបរអតិថិជន
- ស្នើសុំអតិថិជនដាក់លិខិតសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើមដំកល់ទុក និងចេញបង្កាន់ដៃដាក់ដំកល់ប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិជូនអតិថិជន
- ចុះជួបអ្នកធានា ដើម្បីពិនិត្យស្ថានភាពដែលអាចធានាបាន
- ពន្យល់អ្នកធានាពីការទទួលខុសត្រូវរបស់គាត់
- សាកសួរអ្នកធានាបន្ថែមពីទំនាក់ទំនងជាមួយអតិថិជន
- សាកសួរព័ត៌មានបន្ថែមពីសាច់ញាតិ អ្នកផ្គត់ផ្គង់ និងអតិថិជនរបស់គាត់
- បញ្ចប់ការបំពេញពាសន្លឹកចុងក្រោយនៃពាក្យស្នើសុំឥណទាន
- វិភាគនិងផ្ទៀងផ្ទាត់ព័ត៌មានទទួលបានតាមប្រភពផ្សេងៗ
- វាយតម្លៃពាក្យស្នើសុំឥណទាននូវចំណុចមួយចំនួនដូចជា ប្រវត្តិអតិថិជន ប្រវត្តិនៃការសងត្រឡប់វគ្គមុន ( អតិថិជនចាស់ ) លក្ខណៈអត្តចរិតរបស់អតិថិជន និង គោលបំណងនៃការប្រើប្រាស់
- វាយតម្លៃលទ្ធភាពសងពីផលចំណេញលើមុខរបររបស់អតិថិជន ពិនិត្យកម្រិតជីវភាពរស់នៅ និងទំហំទ្រព្យសម្បត្តិទាំងអស់របស់អតិថិជន

- ពិនិត្យលើទ្រព្យធានាបំណុល និងអ្នកធានាបំណុល
- វាយតម្លៃលើស្ថានភាពទីផ្សារលើមុខរបររបស់អតិថិជន និងការប្រែប្រួលសេដ្ឋកិច្ច និងនយោបាយ។

❖ ដំណាក់កាលទី៤៖ ការអនុម័តឥណទាន។ ប្រធានផ្នែកឥណទានត្រូវសង្ខេបព័ត៌មានពីអតិថិជន ជូនសមាជិកគណៈកម្មាធិការឥណទាន និងស្នើសុំយោបល់ពីសមាជិកគណៈកម្មាធិការឥណទាន។ បន្ទាប់មកគណៈកម្មាធិការឥណទានប្រចាំសាខា បានផ្តល់យោបល់លើសំណើរសុំអនុម័តឥណទាន ដែលអាចមាន២ករណី គឺ ៖

- ករណីទី១ គឺបដិសេធការស្នើសុំឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា រក្សាទុកឯកសារមិនបានអនុម័ត រួចផ្តល់ចម្លើយទៅភ្នាក់ងារ។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយដោយបដិសេធសំណើរសុំឥណទានទៅកាន់អតិថិជន និងរៀបចំដកប័ណ្ណកម្មសិទ្ធិជូនអតិថិជនវិញ។
- ករណីទី២ គឺយល់ព្រមអនុម័តឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា ត្រូវផ្តល់ចម្លើយទៅអោយភ្នាក់ងារឥណទាន។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយយល់ព្រមអនុម័តឥណទានជូនអតិថិជន។

❖ ដំណាក់កាលទី៥៖ ការរៀបចំឯកសារឥណទាន ។ ភ្នាក់ងារឥណទានត្រូវ ៖

- រៀបចំកិច្ចសន្យាខ្ចីប្រាក់ និងកិច្ចសន្យាដាក់បញ្ចាំ ផ្ទេរសិទ្ធិគ្រប់គ្រង និងយល់ព្រមលក់ទ្រព្យបញ្ចាំ និងអានពន្យល់ឲ្យមានច្បាស់លាស់ជូនអតិថិជន និងអ្នកធានា ស្តាប់មុននឹងផ្តិតមេដៃ
- ឲ្យអតិថិជន និងអ្នកធានា ផ្តិតមេដៃនៅចំពោះមុខលើកិច្ចសន្យាទាំងអស់ និងអត្តសញ្ញាណប័ណ្ណថតចម្លងរួមទាំងចុះកាលបរិច្ឆេទផងដែរ
- ស្នើឲ្យអតិថិជន យកឯកសារទៅបញ្ជាក់អជ្ញាធរមូលដ្ឋាន
- ប្រសិនបើអតិថិជនត្រូវការដកប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើម ស្នើសុំបង្កាន់ដៃដាក់ដំកល់ដើម្បីឲ្យអតិថិជនផ្តិតមេដៃ
- បន្ទាប់មកអតិថិជនត្រូវបញ្ជូនឯកសារឥណទានត្រឡប់មកវិញរួចហើយភ្នាក់ងារឥណទានត្រូវ:

➢ ពិនិត្យកិច្ចសន្យាទទួលពីអតិថិជនទាំងអស់ឡើងវិញ និងថតចម្លង១ច្បាប់សម្រាប់អតិថិជន

➢ កំណត់ពេលបញ្ចេញសាច់ប្រាក់ ទីកន្លែងទទួលប្រាក់ និងឲ្យអតិថិជនភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណនៅពេលទទួលប្រាក់

➢ ស្នើសុំរដ្ឋបាលធ្វើតារាងសងរំលស់ប្រាក់ និងដាក់ប្រាក់សន្សំពីរច្បាប់

➢ រៀបចំសៀវភៅតាមដានការសងប្រាក់ និងការសន្សំប្រាក់សម្រាប់អតិថិជន ដោយចុះកត់ត្រាចំនួនខ្ចី និងសមតុល្យប្រាក់សន្សំឲ្យបានច្បាស់លាស់

➢ បញ្ជូនឯកសារទាំងអស់ទៅប្រធានផ្នែកឥណទានប្រចាំសាខា

- បន្ទាប់មកប្រធានផ្នែកឥណទានប្រចាំសាខា ពិនិត្យនិងផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃឯកសារទាំងអស់ ប្រសិនបើពិនិត្យឃើញថាគ្រប់គ្រាន់ និងត្រឹមត្រូវហើយ ប្រធានផ្នែកឥណទានប្រចាំសាខាត្រូវចុះហត្ថលេខាលើ Checklist
- បន្ទាប់ពីចុះហត្ថលេខារួចហើយ ត្រូវបញ្ជូនមកកាន់រដ្ឋបាលសាខា។ រដ្ឋបាលសាខា ពិនិត្យ និងផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃឯកសារទាំងអស់ ( ប្រសិនបើពិនិត្យ និងផ្ទៀងផ្ទាត់ហើយឃើញថា មិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវនោះ រដ្ឋបាលសាខាបញ្ជូនមកកាន់ប្រធានផ្នែកឥណទានប្រចាំសាខា ហើយប្រធានផ្នែកឥណទានប្រចាំសាខាត្រូវបញ្ជូនមកកាន់ភ្នាក់ងារឥណទានវិញដើម្បីឲ្យភ្នាក់ងារ ឥណទានត្រួតពិនិត្យ និងរៀបចំឯកសារសារឡើងវិញ។ ប្រសិនបើរដ្ឋបាល ពិនិត្យឃើញថា ឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវហើយនោះ រដ្ឋបាលនិងចុះហត្ថលេខាលើ Checklist )
- បន្ទាប់ពីរដ្ឋបាលចុះហត្ថលេខាលើ Checklist រួចហើយ ត្រូវបញ្ជូនទៅកាន់គណនេយ្យករសាខា។ គណនេយ្យករសាខា ពិនិត្យ និងរៀបចំ Cash Disbursement Voucher ( CDV )
- រួចបញ្ជូនទៅប្រធានសាខាចុះហត្ថលេខា និងបោះត្រាលើ Checklist and CDV
- បន្ទាប់មកបញ្ជូនឯកសារទៅបេឡាករសាខា ឬសាខារងដែលអតិថិជននឹងមកទទួល

❖ ដំណាក់កាលទី៦៖ ការបញ្ចេញឥណទាន។ បេឡាករសាខាត្រូវ ៖

- ពិនិត្យឈ្មោះ និងផ្ទៀងផ្ទាត់រូបភាព ( អតិថិជនមកទទួលប្រាក់ ) អ្នកខ្ចីតែម្តង
- ស្នើសុំអតិថិជនផ្តិតមេដៃលើ CDV និងលើតារាងកាលវិភាគសងប្រាក់
- ជូនតារាងកាលវិភាគសងប្រាក់ និងដាក់ប្រាក់សន្សំទៅកាន់អតិថិជន ហើយពន្យល់ពីរបៀបអាន និងរបៀបគណនាក្នុងតារាងនោះ
- ជូនកិច្ចសន្យាថតចម្លងទៅអតិថិជន
- ពិនិត្យចំនួនខ្ចី និងសមតុល្យប្រាក់សន្សំនៅក្នុងសៀវភៅតាមដាន ការសងប្រាក់ ហើយពន្យល់ពីអត្ថប្រយោជន៍នៃសៀវភៅ និងការរក្សាសៀវភៅឲ្យបានល្អ មុនជូនឲ្យអតិថិជន
- រំលឹកពីគោលការណ៍សងប្រាក់ ថ្ងៃសងប្រាក់ ទីកន្លែង និងយកសៀវភៅតាមដានការសងប្រាក់ត្រឡប់មកវិញពេលទូទាត់ប្រាក់
- ផ្តល់ប្រាក់ដល់អតិថិជន
- ថ្លែងអំណរគុណអតិថិជនពីការប្រើប្រាស់សេវាកម្មក្រុមហ៊ុន ឬធនាគារ

- បេឡាករសាខា ឬសាខារង ត្រូវផ្តល់ឯកសារឥណទានដល់រដ្ឋបាលប្រចាំសាខាដើម្បីរក្សាទុក
- រដ្ឋបាលប្រចាំសាខា ចុះក្នុងបញ្ជីតាមដានការប្រគល់ និងដកប័ណ្ណសម្គាល់កម្មសិទ្ធិនូវទ្រព្យសម្បត្តិដែលទទួលពីបេឡាករ ឬភ្នាក់ងារឥណទាន
- រដ្ឋបាលប្រចាំសាខាឥណទាន រក្សាឯកសារឥណទានរបស់អតិថិជនជាមួយឯកសារឥណទានពីវគ្គមុនជាមួយគ្នា ( រួមគ្នា )

❖ ដំណាក់កាលទី៧៖ ការតាមដានអតិថិជន ។ ភ្នាក់ងារឥណទានដែលទាក់ទងត្រូវ ៖

- ចុះសួរសុខទុក្ខអតិថិជន ១សប្តាហ៍យ៉ាងយូរបំផុត ក្រោយចេញឥណទាន និងតាមដានឲ្យបានទៀងទាត់ជារៀងរាល់ខែម្តងយ៉ាងតិចបំផុត
- សាកសួរពីការវិវត្តិន៍លើមុខរបរ
- សង្កេតមើលការប្រើប្រាស់ឥណទាន
- សរសេរជារបាយការណ៍សង្ខេបជូនទៅប្រធានផ្នែកឥណទានប្រចាំសាខា។

❖ ដំណាក់កាលទី៨៖ ការសងឥណទានត្រឡប់វិញ។ ក្នុងដំណាក់កាលនៃការសងឥណទានត្រឡប់មកវិញមាន២ករណី គឺ៖

- ករណីទី១៖ អតិថិជនមកទូទាត់ប្រាក់។ បេឡាករសាខាត្រូវ :

➢ ពិនិត្យសៀវភៅតាមដានការសងប្រាក់ និងគណនាចំនួនប្រាក់ដែលត្រូវទូទាត់
➢ កត់ត្រាចំនួនសងនៅក្នុងសៀវភៅឥណទាន
➢ ទទួលប្រាក់ពីអតិថិជន
➢ ចេញប័ណ្ណទទួលប្រាក់ជូនអតិថិជន
➢ ស្នើសុំអតិថិជនផ្តិតមេដៃលើប័ណ្ណទទួលប្រាក់
➢ រំលឹកពីថ្ងៃត្រូវសងប្រាក់នូវខែបន្ទាប់
➢ ថ្លែងអំណរគុណអតិថិជនចំពោះការទូទាត់ប្រាក់តាមកាលកំណត់។

- ករណីទី២៖ អតិថិជនមិនមកទូទាត់ប្រាក់។ បេឡាករសាខាត្រូវ ៖

➢ ពិនិត្យសៀវភៅតាមដានឥណទាន
➢ ធ្វើរបាយការណ៍ពីអតិថិជនមិនមកទូទាត់ប្រាក់
➢ ផ្តល់របាយការណ៍ទៅភ្នាក់ងារដែលទទួលខុសត្រូវនៅចុងថ្ងៃនីមួយៗ

- ភ្នាក់ងារឥណទានដែលទាក់ទងត្រូវ ៖

➢ ចុះជួបអតិថិជនពេលទទួលបានរបាយការណ៍ ឬ នៅថ្ងៃបន្ទាប់ពីទទួលរបាយការណ៍

- ➢ សាកសួរអតិថិជនពីមូលហេតុដែលពុំបានទូទាត់ប្រាក់
- ➢ រំលឹកពីរបាយការណ៍ឥណទានរបស់ក្រុមហ៊ុនសម្រាប់ការខកខានមិនបានទូទាត់
- ➢ ស្វែងរកដំណោះស្រាយជាមួយអតិថិជនដើម្បីឲ្យទូទាត់ប្រាក់បានឆាប់។ ក្រោយពីរកដំណោះស្រាយរួចហើយ ប្រសិនបើ ៖

- អតិថិជនសន្យាយល់ព្រមទូទាត់ ភ្នាក់ងារឥណទានត្រូវ :
- ✓ ធ្វើកិច្ចសន្យាទូទាត់ប្រាក់ថ្មីជាមួយអតិថិជន
- ✓ ជូនដំណឹងមកប្រធានផ្នែកឥណទាន
- ✓ តាមដានការសងរបស់អតិថិជនជាប្រចាំ
- ✓ ចុះក្រើនរំលឹកអតិថិជនឲ្យបានញឹកញប់
- អតិថិជនផ្តល់ដំណោះស្រាយមិនអាចទទួលយកបាន ភ្នាក់ងារឥណទានត្រូវ រាយការណ៍មកប្រធានផ្នែកឥណទាន និងគណកម្មធិការឥណទានប្រចាំសាខា
- ✓ បន្ទាប់មកគណកម្មាធិការឥណទានប្រចាំសាខា និងភ្នាក់ងារត្រូវ ចុះជួបអតិថិជន និងអ្នកធានាដើម្បីស្វែងរកដំណោះស្រាយថ្មី បន្ទាប់មកស្នើសុំឲ្យអតិថិជនស្វែងរកជំនួយពីសាច់ញាតិ ឬអ្នកធានា។ ប្រសិនបើលទ្ធផលអាចទទួលយកបាន បំណុលត្រូវបានសងរួចរាល់។ តែបើសិនជាលទ្ធផលមិនអាចទទួលយកបានវិញ គណកម្មាធិការឥណទានប្រចាំសាខា និងភ្នាក់ងារ ត្រូវ :
- ▪ ស្នើឲ្យអតិថិជនលក់ទ្រព្យចលនវត្ថុនានា ដែលអាចលក់បានឆាប់រហ័សដើម្បីទូទាត់បំណុល
- ▪ ក្នុងករណីមិនមាន ឬទ្រព្យនោះមិនគ្រប់គ្រាន់ ស្នើឲ្យអតិថិជនធ្វើការដោះស្រាយបំណុលដោយស្វែងរកអ្នកទិញទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំ
- ▪ ស្នើឲ្យអ្នកធានាទទួលខុសត្រូវលើបំណុលជាមួយ។

ប្រសិនបើអតិថិជនយល់ព្រមតាមសំណើរសុំខាងលើ គណកម្មាធិការឥណទានប្រចាំសាខា និងភ្នាក់ងារ ត្រូវ :

- ✓ ធ្វើកិច្ចសន្យាសងថ្មី
- ✓ កំណត់កាលវេលាសងប្រាក់ជាមួយអតិថិជន
- ✓ តាមដានមើលការវិវត្តលើកិច្ចសន្យាថ្មីជាប្រចាំ បំណុលត្រូវបានសងចប់។

### ១.៥.៣.គោលការណ៍នៃការផ្តល់ឥណទាន[13]

ដោយឥណទានទាក់ទងនឹងការខ្ចីបុល ដោយការសងត្រឡប់ទៅវិញទាំងដើមទាំងការ តាមការកំណត់ ដូចនេះ គេត្រូវមានគោលការណ៍ដើម្បីធានាសុវត្ថិភាព និងទ្រព្យធនរបស់អ្នកឲ្យខ្ចី។ គេចែកគោលការណ៍ឥណទានជា ៥ ផ្នែកដូចខាងក្រោម ៖

#### ១.៥.៣.១.គោលការណ៍នៃការផ្តល់ឥណទានមានគោលដៅ និងផែនការ

តាមគោលការណ៍នេះ អង្គភាពអាជីវកម្មទាំងអស់ ឬផ្នែកឯកជននៅក្នុងវិស័យសេដ្ឋកិច្ច ចង់ខ្ចីប្រាក់ពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាច់ខាតត្រូវធ្វើពាក្យសុំខ្ចីដោយយល់មូលហេតុច្បាស់លាស់ពីបំណង និងទិសដៅប្រើប្រាស់កម្ចីនោះ ព្រមទាំងពេលវេលាដែលត្រូវសងប្រាក់វិញ។ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវធ្វើដំណើរការត្រួតពិនិត្យពាក្យសុំខ្ចីឲ្យបានល្អិតល្អន់សិនទើបសម្រេចចិត្តឲ្យខ្ចី ឬមិនឲ្យខ្ចី។ គោលការណ៍នេះ បង្ខំឲ្យអ្នកខ្ចីត្រូវរាយការណ៍តួលេខ និងស្ថានភាពហិរញ្ញវត្ថុរបស់អង្គការ ឬ គ្រួសាររបស់ខ្លួន ឲ្យធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដឹង។ ការត្រួតពិនិត្យផែនការ ឬគោលដៅប្រើប្រាស់ទុនជួបការលំបាកខ្លះ ព្រោះស្ថាប័នហិរញ្ញវត្ថុ និងរដ្ឋាភិបាលមិនអាចធ្វើអន្តរាគមន៍នៅក្នុងសកម្មភាពរបស់ពួកគាត់បានទេ។

#### ១.៥.៣.២.គោលការណ៍នៃការផ្តល់ឥណទានដោយសងវិញទាំងដើម ទាំងការ

នេះជាគោលការណ៍សំខាន់បំផុតរបស់ឥណទាន។ គោលការណ៍នេះ បង្ខំឲ្យអ្នកខ្ចីត្រូវគិតប្រើប្រាស់ទុនខ្ចីឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីធ្វើយ៉ាងណាឲ្យផលិតផល និងអាជីវកម្មរបស់គេបានចំណេញទើបមានលទ្ធភាពសងទាំងដើម ទាំងការ ទៅឲ្យម្ចាស់ចំណុលវិញ។ គោលការណ៍នេះមានន័យចំពោះអ្នកសុំខ្ចីប្រាក់ផង និងអ្នកឲ្យខ្ចីផង ដោយផ្អែកលើមូលដ្ឋានកូនបំណុលត្រូវសងតាមពេលវេលាកំណត់ទាំងដើម ទាំងការ។

#### ១.៥.៣.៣.គោលករណ៍នៃការផ្តល់ឥណទានដោយមានការធានា

គោលការណ៍នេះ ទោះបីជាទំហំទឹកប្រាក់ប៉ុណ្ណាក៏ដោយ អ្នកខ្ចីត្រូវមានការធានាលើបំណុលរបស់ខ្លួន ដូចជាធានាដោយសម្ភារៈ ទំនិញ បញ្ចាំដោយចលនទ្រព្យ ឬត្រូវបានធានាចេញសងដោយអ្នកធានា។ ការអនុវត្តគោលការណ៍នេះ ត្រូវធ្វើឲ្យបានសមស្របទៅនឹងភាពជាក់ស្តែងណាមួយ។ គោលការណ៍ឥណទានទាំងបីដូចដែលបានរៀបរាប់ខាងលើនេះ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយឥណទាននោះត្រូវបានសើរើមើលតាមកាលវិភាគដែលបានកំណត់ទាល់តែដល់ពេលកំណត់ត្រូវសង។ បែបបទនៃការសើរើឥណទានមានច្រើនយ៉ាង តែគោលការណ៍ទូទៅមួយចំនួនដែលធនាគារច្រើនលើកយកមកអនុវត្តន៍មានដូចជា ៖

[13] រុន សិរីមាលា និងសុខ ថានីន, ២០១១, " ការផ្តល់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច ", ទំព័រ ១៨-២១

១. អនុវត្តន៍សើរើឥណទានគ្រប់ប្រភេទទាំងអស់តាមកាលកំណត់។ ឧទាហរណ៍ សើរើម្តងក្នុងរយៈពេល ៣០ ថ្ងៃ ឬ ៩០ថ្ងៃ ។

២. ត្រូវរៀបចំយ៉ាងណា ដើម្បីធានាទិដ្ឋភាពសំខាន់ៗនៃឥណទាននីមួយៗ និងត្រូវបានពិនត្យមើលយ៉ាងត្រឹមត្រូវ។ ទិដ្ឋភាពទាំងនោះមានដូចជា៖

- បញ្ជីសងបំណុលរបស់អ្នកខ្ចីប្រាក់ដើម្បីឲ្យប្រាកដថា កូនបំណុលបានសងត្រឹមត្រូវតាមកាលកំណត់
- គុណភាព និងលក្ខណៈនៃវត្ថុធានា
- សំណុំឯកសារខ្ចីប្រាក់ត្រូវមានគ្រប់គ្រាន់ ដើម្បីឲ្យធនាគារមានសិទ្ធិអំណាចស្របច្បាប់ក្នុងការប្តឹងទាមទារដកហូតវត្ថុបញ្ចាំ ក្នុងករណីអ្នកខ្ចីមិនព្រមសងបំណុលវិញ
- ធ្វើការវាយតម្លៃថា តើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីមានការប្រែប្រួលដែរឬទេ ? ដែលអាចធ្វើឲ្យតម្រូវការឥណទានរបស់ខ្ចីប្រាក់កើនឡើង ឬ ថយចុះ
- ធ្វើការវាយតម្លៃថា តើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនោះសមស្របទៅនឹងនយោបាយឥណទានដែលបានកំណត់ដែរឬទេ? ហើយសមស្របទៅនឹងស្តង់ដារដែលអ្នកត្រួតពិនិត្យឥណទានបានអនុវត្តន៍ចំពោះប្រតិបត្តិការផ្តល់កម្ចីដែរឬទេ?

៣. សើរើមើលឲ្យបានញឹកញាប់បំផុតចំពោះឥណទានធំៗ ពីព្រោះបើចំណុចធំៗមិនអាចទារបាននោះ វានឹងមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពទាំងមូល។

៤. ធ្វើការសើរើឲ្យបានញឹកញាប់បំផុតចំពោះបំណុលដែលមានបញ្ហា។

៥. បង្កើនការសើរើមើលឥណទាន ប្រសិនបើសេដ្ឋកិច្ចកំពុងធ្លាក់ចុះ ឬ បើសិនជាឧស្សាហកម្មដែលជារបរអាជីវកម្មរបស់អតិថិជនកំពុងជួបបញ្ហា ដូចជា មានអ្នកប្រកួតប្រជែងថ្មី ឬការប្រែប្រួលបច្ចេកវិទ្យាជាដើម។

### ១.៥.៣.៤.គោលការនៃការប្រមូលប្រាក់បំណុល

ការប្រមូលបំណុល គឺធ្វើឡើងអាស្រ័យទៅនឹងកាលបរិច្ឆេទទូទាត់បំណុលដែលបានកំណត់។ អ្នកគ្រប់គ្រងឥណទានរក្សាទុកនូវរបាយការណ៍នៃបទពិសោធន៍កន្លងមក ក្នុងការទូទាត់សងរបស់កូនបំណុលនីមួយៗ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ តែងតែអនុវត្តន៍តាមនីតិវិធីពេលដែលអតិថិជនមិនអាចមានលទ្ធភាពសងបំណុលវិញបាន ។ នីតិវិធីទាំងនោះមានដូចខាងក្រោម ៖

- បញ្ជូនភ្នាក់ងារឥណទានទៅដាស់តឿនអតិថិជនដល់កន្លែង
- ផ្ញើលិខិតបញ្ជាក់ពីការហួសពេលកំណត់សង
- ប្តឹងតាមនីតិវិធីទោតុលាការ។

#### ១.៥.៣.៥.គោលការណ៍ផាកពិន័យចំពោះការសងបំណុលយឺតយ៉ាវ និងការខកខានមិនបានសង

អតិថិជនមិនអាចខកខាន ( យឺតយ៉ាវ ) ក្នុងការបង់ប្រាក់តាមពេលវេលាដែលបានកំណត់ឡើងនោះឡើយ ប្រសិនបើមានការខកខានក្នុងការសងប្រាក់ចាប់ពីមួយថ្ងៃឡើងទៅ អតិថិជននោះនឹងត្រូវផាកពិន័យលើការបង់យឺតយ៉ាវ។

អតិថិជនដែលសងយឺតយ៉ាវចាប់ពីមួយថ្ងៃឡើងទៅ នោះស្ថាប័ននឹងធ្វើការផាកពិន័យទៅតាមគោលការណ៍ដែលស្ថាប័ននីមួយៗបានកំណត់។

### ១.៥.៤.ការវាយតម្លៃឥណទាន[14]

ដើម្បីធ្វើឲ្យការផ្តល់កម្ចីដំណើរការទៅប្រកបដោយគុណភាព ទាមទារឲ្យយើងប្រើប្រាស់នូវការវិនិច្ឆ័យទៅលើចំណុចសំខាន់ៗចំនួន៥ គឺរួមមាន ចរិកលក្ខណៈ សមត្ថភាព ដើមទុន វត្ថុបញ្ចាំ និងលក្ខខណ្ឌ។

ចំណុចទាំងអស់ខាងលើនេះនឹងជួយក្នុងការគ្រប់គ្រងឥណទាន បំពេញភារកិច្ចត្រួតពិនិត្យបានឆាប់រហ័ស ដើម្បីបញ្ជាក់ ប្រសិនបើព័ត៌មានណាមួយមើលរំលង និងបញ្ជាក់ពីគុណភាពឥណទានដែលមានតម្រូវការនៃការសើបអង្កេតមុននឹងសម្រេចចិត្តផ្តល់ឥណទាន។

## ១.៦.វិធីសាស្ត្រសងរំលស់នៃឥណទាន[15]

### ១.៦.១.បំណុលដែលសងតែម្តងគត់នៅកាលអវសាន ( Pure Discount Laon )

បំណុលដែលសងតែម្តងគត់នៅកាលអវសាន គឺជាទម្រង់ដ៏សាមញ្ញបំផុតរបស់ឥណទាន។ ជាមួយនឹងកម្ចីប្រភេទនេះ អ្នកខ្ចីទទួលបានសាច់ប្រាក់នៅថ្ងៃនេះ ឬពេលបច្ចុប្បន្ន ហើយត្រូវទូទាត់សងទៅម្ចាស់បំណុលវិញនូវចំនួនសរុបនៃទឹកប្រាក់ ( ការប្រាក់ បូកប្រាក់ដើម ) នៅកាលកំណត់ណាមួយនាពេលអនាគតដែលបានព្រមព្រៀងទុក។

### ១.៦.២.បំណុលសងតែការប្រាក់ ( Interest-Only Laon )

ប្រភេទទីពីរនៃការសងបំណុល គឺបំណុលដែលសងតែការប្រាក់ វាគឺជាវិធីសាស្ត្រម៉្យាងដែលអនុញ្ញាតឲ្យអ្នកខ្ចីបង់សងតែការប្រាក់ទៅតាមគ្រា ឬខែនីមួយៗ ហើយសងប្រាក់ដើមទាំងអស់នៅកាលកំណត់ណាមួយនាពេលអនាគត ដែលបានព្រមព្រៀងគ្នាទុក។

---

[14] ហុង ម៉ូលីកា និងសឿង សុខឃីម, ២០១៩, " ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ", ទំព័រ ២០

[15] លោកសាស្ត្រាចារ្យ ព្រុំ សុគុណ, ២០១២, " Fundamentals of Corporate Finance ", ទំព័រ ១៨-២២

### ១.៦.៣.បំណុលសងរំលស់

ជាមួយនឹងបំណុលដែលសងតែម្តងគត់នៅកាលអវសាន ( Pure Discount Laon ) និងបំណុលដែលសងតែការប្រាក់ ប្រាក់ដើមសរុបទាំងអស់ គឺត្រូវសងតែម្តងនៅគ្រាណាមួយនាពេលអនាគត។ ជម្រើសនៃការសងបំណុលមួយទៀត គឺសងរំលស់ ដែលការសងប្រភេទនេះ ម្ចាស់បំណុលតម្រូវឲ្យអ្នកខ្ចីប្រាក់ធ្វើការសងត្រឡប់មកវិញជាផ្នែកៗ គ្រប់ពេលវេលាដែលបានកំណត់។ ការសងរំលស់មាន២យ៉ាងគឺ ការសងរំលស់ប្រាក់ដើមស្មើៗគ្នាប្រចាំគ្នា និងការសងរំលស់ដែលមានសំណាងស្មើៗគ្នា។

## ១.៧.ការគ្រប់គ្រងហានិភ័យឥណទាន

### ១.៧.១.និយមន័យ

[16]ហានិភ័យឥណទាន គឺជាប្របាប៊ីលីតេដែលអាចកើតឡើងចំពោះ ធនាគារ ឬ មីក្រូហិរញ្ញវត្ថុ ដែលធ្វើឲ្យទទួលរងនូវការខាតបង់ដោយសារអតិថិជនរបស់ខ្លួនមិនសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន ឬសងមិនគ្រប់ចំនួនទឹកប្រាក់ដើម និងការប្រាក់។

[17]ហានិភ័យឥណទាន គឺជាកម្រិតនៃគ្រោះថ្នាក់ដែលអាចកើតមានឡើងចំពោះប្រាក់កម្ចីរបស់ធនាគារ ឬ មីក្រូហិរញ្ញវត្ថុ ដោយទទួលរងនូវការខាតបង់ ដោយអតិថិជនរបស់ខ្លួនមិនសងបំណុលតាមកិច្ចសន្យា ឬ សងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើម ទាំងការ។ ហានិភ័យនេះ ជាហានិភ័យដែលធនាគារ និង មីក្រូហិរញ្ញវត្ថុ យកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចធ្វើឲ្យធនាគារ ឬ មីក្រូហិរញ្ញវត្ថុ អាចក្ស័យធនបាន។ ដូចនេះមុននឹងសម្រេចចិត្តផ្តល់ឥណទាន គេតែងតែសិក្សាទៅលើហានិភ័យជាចម្បង លុះត្រាតែធនាគារ ឬមីក្រូហិរញ្ញវត្ថុ យល់ឃើញថាគ្មានហានិភ័យ ឬមានហានិភ័យទាបទើបគេផ្តល់ឥណទាន។

### ១.៧.២.មូលហេតុដែលបណ្តាលឲ្យមានហានិភ័យ[18]

#### ១.៧.២.១.មូលហេតុបណ្តាលមកពីអតិថិជន

- ការព្យាករណ៍ ឬការវាយតម្លៃលើការវិនិយោគនៅទាប ( គំនិតក្នុងការវិនិយោគនៅស្ទើមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ )
- មិនសូវមានការពិចារណាឲ្យបានស៊ីជម្រៅទៅលើការវិនិយោគណាមួយ ឬចូលចិត្តការវិនិយោគណាដែលមានប្រាក់ចំណេញច្រើន

[16] លោកសាស្ត្រាចារ្យ សួន ចំរើន, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ១៤

[17] លោកសាស្ត្រាចារ្យ ងួន ហេង, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ៨២

[18] លោកសាស្ត្រាចារ្យ សួន ចំរើន, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ២៤

- អាចត្រូវដៃគូ ឬ អ្នកវិនិយោគដទៃទៀតបោកប្រាស់
- ការប្រើប្រាស់លុយខុសគោលដៅ
- អតិថិជនខ្លះមានគោលបំណងមិនសងប្រាក់ធនាគារ ទោះបីជាមានលទ្ធភាពសងក៏ដោយ
- គ្រួសារ ឬសមាជិកណាមួយក្នុងគ្រួសារត្រូវការលុយក្នុងការមើលជម្ងឺ។

**១.៧.២.២.មូលហេតុបណ្តាលមកពីធនាគារ**

- បុគ្គលិកពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីវាយតម្លៃអតិថិជន ឬការវិនិច្ឆ័យមិនបានត្រឹមត្រូវ
- បុគ្គលិកមានចេតនាធ្វើឲ្យមានកំហុស ពុំមានភាពស្មោះត្រង់
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន ត្រួតពិនិត្យបំណុលទាន់ពេលវេលា។

**១.៧.២.៣.មូលហេតុដែលបណ្តាលមកពីសេដ្ឋកិច្ច សង្គម និង គ្រោះធម្មជាតិ**

- សេដ្ឋកិច្ចៈ កាលណាមានវិបត្តិសេដ្ឋកិច្ចកើតឡើង នាំឲ្យបណ្តាក្រុមហ៊ុន សហគ្រាស ប្រឈមមុខនឹងការកក្ស័យធន ព្រោះថាតម្រូវការអតិថិជនមានការធ្លាក់ចុះ ដែលជាមូលហេតុធ្វើឲ្យចំណូលផ្ទាល់ខ្លួន និងចំណូលក្រុមហ៊ុនធ្លាក់ចុះ។ ដូច្នេះ ក្រុមហ៊ុនពុំមានលទ្ធភាពសងបំណុល ធនាគារ។
- សង្គមៈ មានដូចជាសង្គ្រាម មានការប្រែប្រួលនៃសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល នយោបាយ។
- គ្រោះធម្មជាតិៈ ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ផ្ទុះ នាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងដោយសារអាជីវកម្ម ឬមុខរបរត្រូវបានផ្អាកដំណើរការ[19]។

### ១.៧.៣.ផលប៉ះពាល់ដែលបណ្តាលឲ្យមានហានិភ័យឥណទាន[20]

នៅពេលដែលមានហានិភ័យមានទំហំកាន់តែធំឡើងៗ នឹងនាំឲ្យមានផលប៉ះពាល់ដូចខាងក្រោម ៖

- **បង្កើតចំណាយបន្ថែមសម្រាប់ប្រតិបត្តិការដូចជាៈ**
  - ភ្នាក់ងារចំណាយពេលច្រើនដើម្បីតាមដាន
  - ភ្នាក់ងារមិនមានពេលសម្រាប់បញ្ចេញឥណទានថ្មីទៀត
  - រំលស់យានយន្ត ក្រដាសស្នាម ប្រេងឥន្ទនៈ ថ្លៃប្រថាប់ត្រា និងរត់ការផ្សេងៗកើនឡើង
- **ខូចកេរ្តិ៍ឈ្មោះធនាគារ**
  - ក្រមសីលធម៌ភ្នាក់ងារអាចនឹងធ្លាក់ចុះពេលមានវិវាទកើតឡើង
  - បុគ្គលិកអាចមិនស្តាប់បង្គាប់អ្នកគ្រប់គ្រង ព្រោះអស់សង្ឃឹមក្នុងវិជ្ជាជីវៈ

[19] សុខ ចំរើន និងឡេង សុភក្រ, ២០១៣, " ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ", ទំព័រ ៥៦-៥៧

[20] កាន់ ដានី និងឡេង ណាឌី, ២០១២, " នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជក្រៅប្រទេសនៃកម្ពុជា "

- អតិថិជនមិនមានជំនឿលើធនាគារ ហើយមិនហ៊ានមកដាក់ប្រាក់បញ្ញើ
- អតិថិជនធ្លាប់សងទៀងទាត់បែរជាសងមិនទៀតទាត់តាមគេឯងវិញ

❖ **សរុបលទ្ធផល**

- បាត់បង់ទីផ្សារ , ចំណូលពីការប្រាក់ថយចុះ
- គ្មានមូលនិធិសងការប្រាក់បញ្ញើ , ប្រាក់ចំណេញរបស់ធនាគារទាប
- អតិថិជនដកប្រាក់ប្រាក់បញ្ញើចេញពីធនាគារ
- ក្ស័យធន និងបុគ្គលិកគ្មានការងារធ្វើ។

### ១.៧.៤.យុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យឥណទាន[21]

❖ **ចំពោះអតិថិជន**

- ធ្វើការវាយតម្លៃឲ្យត្រឹមត្រូវពីអតិថិជនដូចជា៖
  - គោលបំណងនៃការសុំខ្ចី
  - វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
  - ពិចារណាលើគោលជំហរអ្នកសុំខ្ចី ( ប្រវត្តិរូប )
  - ផែនការគម្រោង
- ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា
- ផ្តល់យោបល់ក្នុងករណីផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មរបស់អតិថិជន

❖ **ចំពោះធនាគារ**

- ពង្រឹងសមត្ថភាពបុគ្គលិក ដែលមានចំណេះដឹងផ្នែកឥណទាន
  - ជ្រើសរើសបុគ្គលិកដែលមានចំណេះដឹងផ្នែកឥណទាន
  - បណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ការដាក់ទោសចំពោះបុគ្គលិកដែលមានកំហុស
- ការលើកទឹកចិត្តចំពោះបុគ្គលិកដែលខិតខំប្រឹងប្រែងធ្វើការ

❖ **ចំពោះសេដ្ឋកិច្ច-សង្គម**

- វិបត្តិសេដ្ឋកិច្ច
- អសន្តិសុខសង្គម

---

[21] លោកសាស្ត្រាចារ្យ សួន ចំរើន, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ២៥

- គ្រោះថ្នាក់ធម្មជាតិ។

## ១.៨.វិធីសាស្ត្រគិតការប្រាក់

### ១.៨.១.និយមន័យ

[22]ការប្រាក់ គឺជាចំនួននៃសាច់ប្រាក់ដែលអ្នកខ្ចីប្រាក់បង់ទៅឲ្យម្ចាស់បំណុលសម្រាប់ការ ប្រើប្រាស់បណ្ដោះអាសន្ននៃប្រាក់របស់ម្ចាស់បំណុល។ ម៉្យាងទៀត ការប្រាក់គឺជាថ្លៃឈ្នួលដែលអ្នកខ្ចីបង់ទៅឲ្យម្ចាស់បំណុលសម្រាប់ការប្រើប្រាស់សាច់ប្រាក់។

[23]ការប្រាក់ គឺជាប្រាក់ដែលកូនបំណុលសងទៅម្ចាស់បំណុលជាឈ្នួលនៃការប្រើប្រាស់លុយរបស់គេ។

### ១.៨.២.ការប្រាក់ធម្មតា ( Simple Interest )[24]

រូបមន្តសម្រាប់គណនាការប្រាក់ធម្មតាគឺ ៖

| ការប្រាក់ = ប្រាក់ដើម x អត្រាការប្រាក់ x រយៈពេល ( គិតជាឆ្នាំ ) |
|---|

ចំនួនប្រាក់សរុបពេលអនាគត = ប្រាក់ដើម + ការប្រាក់

= ប្រាក់ដើម + ( ប្រាក់ដើម x អត្រាការប្រាក់ x រយៈពេល )

= ប្រាក់ដើម + [( ១+ អត្រាការប្រាក់ ) x រយៈពេល ]

ដូចនេះគេបានរូបមន្តសម្រាប់កម្ចីធម្មតាចំនួនប្រាក់សរុប = $P \times (1+rt)$

P= ជាប្រាក់ដើម

r= ជាអត្រាការប្រាក់

t= ជារយៈពេល

### ១.៨.៣.ការប្រាក់ផ្ទួប ( Compound Interest )[25]

---

[22] ហុង ម៉ូលីកា និងសឿង សុខឃីម, ២០១៩, " ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ", ទំព័រ ២៤

[23] លោកសាស្ត្រាចារ្យ ព្រុំ សុគុណ, ២០១១, " គណិតវិទ្យាហិរញ្ញវត្ថុ ", ទំព័រ ២០

[24] លោកសាស្ត្រាចារ្យ ងួន ហេង, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ៣៣-៣៤

[25] លោកសាស្ត្រាចារ្យ ងួន ហេង, ២០១១, " រូបិយវត្ថុ និងធនាគារ ", ទំព័រ ៦៣-៦៤

ការប្រាក់ផ្គួប គឺជាការប្រាក់មួយប្រភេទដែលធ្វើឲ្យសាច់ប្រាក់មានកំណើនលឿន ព្រោះវាទទួលបានការប្រាក់លើការប្រាក់។ ដោយសារតែគិតជាការប្រាក់ផ្គួប ការប្រាក់ដែលទទួលបាននៅចុងឆ្នាំ និងបូកបញ្ចូលទៅក្នុងប្រាក់ដើម ដែលអាចឲ្យអ្នកទទួលបានការប្រាក់លើការប្រាក់ដែលបូកបញ្ចូលទៅក្នុងប្រាក់ដើមនៅឆ្នាំបន្ទាប់។

ធនាគារ ជាធម្មតាបង់ការប្រាក់ផ្គួបទៅឲ្យអ្នកដាក់ប្រាក់បញ្ញើ ដែលបើកគណនីសន្សំនៅធនាគារ។ ការប្រាក់ដែលអ្នកដាក់ប្រាក់បញ្ញើទទួលបាននឹងត្រូវបញ្ចូលទៅក្នុងប្រាក់ដើមតាមរយៈពេលដែលបានកំណត់ ហើយការប្រាក់នេះនឹងទទួលបានការប្រាក់បន្ថែមទៀត។

| រូបមន្ត៖ | $FV = PVx(1+r)^t$ |
|---|---|

ដែល FV = ប្រាក់សរុបពេលអនាគត

PV = ជាប្រាក់ដើម

r = ជាអត្រាការប្រាក់ និង t = ជារយៈពេល

## ១.៩.វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា[26]

បំណុលមានបញ្ហា កើតឡើងដោយសារតែការខ្វះខាតសាច់ប្រាក់របស់កូនបំណុលក្នុងការទូទាត់សង។ គេមានវិធីសាស្ត្រច្រើន ដើម្បីដោះស្រាយជាមួយកូនបំណុលមានបញ្ហាដូចខាងក្រោម៖

- **ការដោះស្រាយជាមួយអតិថិជន:** នៅពេលដែលកើតមានឡើងនូវឥណទានមានបញ្ហា វិធីសាស្ត្រដំបូងនោះ គឺត្រូវដោះស្រាយជាមួយអតិថិជនដោយផ្ទាល់ ដោយពិនិត្យមើលទៅលើឥណទានដែលមានបញ្ហានោះ តើវាបណ្តាលមកពីមូលហេតុអ្វី? ហើយមន្ត្រីឥណទានត្រូវប្រមូលព័ត៌មានអំពីអតិថិជនរបស់ខ្លួនបន្ថែមទៀត និងរកមូលហេតុដែលបង្កបញ្ហានោះ។ មន្ត្រីឥណទានត្រូវដោះស្រាយដោយសម្រួលជាមួយកូនបំណុល តែបើកូនបំណុលនោះនៅតែមិនព្រមសង មន្ត្រីឥណទានត្រូវនិយាយប្រាប់គាត់ពីការប្តឹងឡើងទៅតុលាការ ដើម្បីរឹបអូសនូវវត្ថុបញ្ចាំនោះ។ ប៉ុន្តែបើសិនជាកូនបំណុលនៅតែមិនព្រមសងទៀត មន្ត្រីឥណទានត្រូវពឹងផ្អែកទៅលើរដ្ឋអំណាច ពីព្រោះថានៅពេលផ្តល់កម្ចីឲ្យអតិថិជនមានការទទួលដឹងឮពីខាងរដ្ឋអំណាចមានដូចជា ប្រធានភូមិ ប្រធានឃុំឬចៅសង្កាត់ជាដើម។ ផ្ទុយទៅវិញ បើកូនបំណុលមានបញ្ហានោះបង្កឡើងដោយគ្រោះធម្មជាតិវិញនោះ គឺគេអាចជួយសម្រួលពន្យាពេលទូទាត់សងដល់គាត់បាន។

[26] ចាប សុវណ្ណលីដា និងឡង់ សុធីរ៉ា, ២០១២, " ឥណទានមុខជំនួញខ្នាតតូច ", ទំព័រ ២១

- **ការផ្តល់លទ្ធភាពជូនអតិថិជន:** ការផ្តល់លទ្ធភាពដល់កូនបំណុលទូទាត់សងនៅពេលគាត់ប្រមូលទិន្នផលបាន។ មន្ត្រីឥណទាន ត្រូវសាកសួរកូនបំណុលអំពីមូលហេតុរបស់គាត់ ហើយត្រូវប្រមូលព័ត៌មានថា តើពេលណាទើបគាត់ប្រមូលផលបាន និងមានលទ្ធភាពអាចសងបំណុលទាន់ពេលវេលាដែលបានព្រមព្រៀងគ្នា។
- **ការផាកពិន័យឲ្យបានខ្លាំង:** ការផាកពិន័យ ក៏ជាបញ្ហាមួយយ៉ាងសំខាន់របស់ធនាគារ ក្នុងការទប់ស្កាត់កុំឲ្យអតិថិជនសងប្រាក់យឺតយ៉ាវដែលជាទម្លាប់អាក្រក់មួយក្នុងការទូទាត់ ហើយការផាកពិន័យនោះក៏មាននៅគ្រប់ស្ថាប័នធនាគារដែរ។ គេយល់ឃើញថាការដាក់កម្រិតនៃការផាកពិន័យនេះ ធ្វើឲ្យអតិថិជនមានការប្រុងប្រយ័ត្ន និងមិនហ៊ានគេចវេសពីការសងបំណុលឡើយ។ ការផាកពិន័យនោះមានដូចជាការផាកពិន័យជាប្រាក់ ឬរឹបអូសយកទ្រព្យបញ្ចាំរបស់កូនបំណុល។

## ១.១០.តួនាទីឥណទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ[27]

ឥណទាន បាននឹងកំពុងក្លាយជាផ្នែកមួយមិនអាចជៀសផុតក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង។ ការប្រើប្រាស់ឥណទានអាចជាផលល្អផង និងផលអាក្រក់ផងដែរ គឺអាស្រ័យលើមូលហេតុនៃតម្រូវការ និង លទ្ធផលទូទាត់របស់អ្នកខ្ចីតាមពេលកំណត់។

ឥណទានបានផ្តល់អត្ថប្រយោជន៍ជាច្រើនសម្រាប់អ្នកប្រើប្រាស់ ការធ្វើជំនួញ និងការអភិវឌ្ឍសេដ្ឋកិច្ច ដូចជា បង្កើនកម្រិតជីវភាពរស់នៅ ដោះស្រាយពេលមានអាសន្ន បង្កើនលទ្ធភាពទីផ្សារជាដើម ដោយយោងលើឥណទានជាប្រេងរអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ដូច្នេះ ឥណទានតែងតែផ្តល់មធ្យោបាយ ដើម្បីស្តែរភាពដល់កម្រិតសកម្មភាពសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ ( អត្រាការប្រាក់ ) ខុសៗគ្នា ហើយជាពិសេស សេវាមានសារៈសំខាន់នៅក្នុងគោលនយោបាយហិរញ្ញវត្ថុ ដើម្បីក្សាលំនឹងថ្លៃនៅលើទីផ្សារ ដែលមានឥទ្ធិពលលើការចំណាយ និងធ្វើការត្រួតពិនិត្យអត្រាការប្រាក់។

[27] ហុង ម៉ូលីកា និងសៀង សុខឃីម, ២០១៩, " ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម ", ទំព័រ ២៧

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារ

## ២.១.ប្រវិត្តសង្ខេប

### ២.១.១.ប្រវត្តសង្ខេបរបស់ABA

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា (សហគ្រាសឯកជន) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1996 មានឈ្មោះថា ធនាគារវឌ្ឍនៈ អាស៊ី ចំកាត់។

ឆ្លងកាត់ការអភិវឌ្ឍនិងកំណើនជាង 20 ឆ្នាំកន្លងមកនេះ ABA បានពង្រឹងជំហររបស់ខ្លួនយ៉ាងរឹងមាំក្នុងទីផ្សារ និងក្លាយជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជកំពូលទាំងបី នៅក្នុងប្រទេស។ សព្វថ្ងៃនេះ ABA មានបម្រើសេវាជូនដល់បណ្តាអតិថិជនជាច្រើនដូចជា សហគ្រាសធុនតូច និងមធ្យម, អាជីវកម្មខ្នាតតូច, និងរូបវន្តបុគ្គល។

សាខាមាន 79, ម៉ាស៊ីនស្វ័យសេវាជាង 280+, ម៉ាស៊ីន ATM ជាង 470+ ទូទាំងប្រទេស, សេវាធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដ៏ទំនើប ធ្វើឲ្យធនាគារ ABA អាចបម្រើអតិថិជនបានកាន់តែច្រើនឡើងៗជាមួយសេវាហិរញ្ញវត្ថុដ៏ទំនើបសម្បូរបែបនេះ។

NATIONAL BANK OF CANADA

ធនាគារ ABA គឺជាបុត្រសម្ព័ន្ធរបស់**ធនាគារជាតិកាណាដា** (www.nbc.ca) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ មានទ្រព្យសកម្មជាង 273 ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី 31 ខែមករា ឆ្នាំ 2021 និងមានបណ្តាញធនាគារសម្ព័ន្ធហិរញ្ញវត្ថុនៅទូទាំងពិភពលោក។ ក្នុងនាមជាភាគហ៊ុនិកមួយរបស់ធនាគារ ABA តាំងពីឆ្នាំ 2014 មក ធនាគារជាតិកាណាដាបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុអាមេរិកខាងជើងទីមួយ ដែលឈានជើងចូលវិស័យធនាគារនៅកម្ពុជា។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្ត នៃប្រទេសជាមួយនឹងអតិថិជនក្នុងដៃ 2.7 លាននាក់។ ជាគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី 6 ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេបិច ធនាគារជាតិកាណាដា ជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានានៅទីនោះ។

នាឆ្នាំ 2017 ធនាគារ ABA ទទួលបានចំណាត់ថ្នាក់ឥណទានរយៈពេលខ្លី និងរយៈពេលវែងកម្រិត 'B' ពីភ្នាក់ងារវាយតម្លៃឥណទាន Standard & Poor's (S&P) Global Ratings។ កម្រិតឥណទានត្រូវបាន ដំឡើងដល់ 'B+' ជាមួយទស្សនវិស័យ "ស្ថិរភាព" ក្នុងឆ្នាំ 2020។
គ្រឹះស្ថានបោះពុម្ពផ្សាយផ្នែកហិរញ្ញវត្ថុដ៏ល្បីល្បាញបំផុតរបស់ពិភពលោក បានទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ ABA ដែលបាននាំយកមកនូវអ្វីដែលល្អបំផុតដល់អតិថិជនរបស់ខ្លួន៖

- នៅឆ្នាំ 2014, 2016 និង 2019 ទស្សនាវដ្តី The Banker បានប្រសិទ្ធិនាមធនាគារ ABA ថាជាធនាគារឆ្នើមប្រចាំឆ្នាំរបស់កម្ពុជា។ ពានរង្វាន់នេះបានទទួលស្គាល់ពីភាពរឹងមាំផ្នែកហិរញ្ញវត្ថុ, ការបន្តនាំមកនូវបច្ចេកវិទ្យាថ្មៃប្រឌិតខ្ពស់, និងការអនុវត្តធុរកិច្ចគំរូ។
- ទស្សនាវដ្តី Euromoney បានផ្តល់ឈ្មោះដល់ធនាគារ ABA ថាជាធនាគារឆ្នើមនៅកម្ពុជា សម្រាប់ឆ្នាំ 2014 - 2021 ដែលមានសេវាកម្មប្រកបដោយគុណភាព, ការច្នៃប្រឌិតថ្មីៗ និងកិច្ចខិតខំប្រឹងប្រែងធ្វើឲ្យសេវាធនាគារកម្ពុជាឈានទ្បើង។
- ទស្សនាវដ្តី Global Finance ប្រសិទ្ធនាម ABA ថាជាធនាគារដែលលេចធ្លោជាងគេនៅក្នុងទីផ្សារ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ 2015 - 2021។ ពានរង្វាន់នេះទទួលស្គាល់ការប្តេជ្ញាចិត្តរបស់ក្រុមការងារនៃធនាគារ ABA ក្នុងការផ្តល់ជូនអតិថិជនរបស់ខ្លួននូវផលិតផលស្របតាមតម្រូវការ និងដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត។
- ទស្សនាវដ្តី Asiamoney ប្រសិទ្ធនាម ABA ថាជាធនាគារឌីជីថលឆ្នើមជាងគេនៅកម្ពុជា ក្នុងឆ្នាំ 2019 - 2020។ ពានរង្វាន់នេះត្រូវបានប្រគល់ជូនធនាគារ ABA សម្រាប់ឥទ្ធិពលគ្របដណ្តប់ផ្នែកឌីជីថលនៅក្នុងវិស័យធនាគារ, ការពង្រីកបណ្តាញសាខា, និងបង្អែកដ៏រឹងមាំពីធនាគារជាតិកាណាដា។

**២.១.២.ប្រវត្តសង្ខេបរបស់ABA សាខាខេត្តពោធិ៍សាត់**

នៅក្រោមការអនុម័តពីធនាគារជាតិ នៃកម្ពុជា ធនាគារ ABA សាខាខេត្តពោធិ៍សាត់បានបើកឲ្យដំណើរការនៅថ្ងៃទី០២ ខែ ឧសភា ឆ្នាំ២០១៤ ។

## ២.២.អត្តសញ្ញាណរបស់ធនាគារ ABA

### ២.២.១.ស្លាកសញ្ញា

ស្លាកសញ្ញាធនាគារ ABA មានរាងប្រអប់បួនជ្រុង ផ្ទៃក្នុងរំលេចដោយពណ៌ខៀវក្រម៉ៅពាក់កណ្តាលទៅក្រោម និងផ្ទៃពណ៌ខៀវស្រាលពាក់កណ្តាលទៅលើ។ ចំកណ្តាលនៃផ្ទៃខៀវក្រម៉ៅ និងផ្ទៃខៀវស្រាលមានរំលេចទៅដោយពណ៌សជិត ABA ស្ថិតនៅខាចលើនៃអក្សរពណ៌សដូចគ្នានៃពាក្យ Bank។ នៅខាលើឆ្វេកខាងស្តាំនៃប្រអប់(Logo) មានពណ៌ក្រហមជិតដែលម្ខាងនៅផ្នែកខាងក្នុងនៃប្រអប់ និងម្ខាងទៀតនៅផ្នែកខាងក្រៅនៃប្រអប់( Logo)។

### ២.២.២.អត្ថន័យនិមិត្តសញ្ញា

- និមិត្តសញ្ញារបស់ធនាគារ ABA មានរាងជាប្រអប់បួនជ្រុងដែលបង្ហាញពីស្ថេរភាព និង សុវត្ថិភាពដែលអាចផ្តល់ឲ្យអតិថិជនតាមរយៈដំបូន្មានល្អៗ និងឱកាសដើម្បីរីកចម្រើន។
- ផ្ទៃពណ៌ខៀវក្រម៉ៅ និងខៀវស្រាល បង្ហាញពីគុណប្រយោជន៍ជាច្រើនដែលអតិថិជនអាចទទួលបានពីធនាគារ ABA ដូចជាវត្តមាននៃដៃគូរ ដែលមានការទទួលខុសត្រូវ និងស្ថិតស្ថេរអស់មួយជីវិត ក៏ដូចជាឱកាសគ្មានដែនកំណត់។
- ពណ៌ក្រហមផ្នែកខាងលើឆ្វេងខាងស្តាំ បានបង្ហាញពីបេះដូងនៃធនាគារ ដែលពោរពេញទៅដោយមនុស្សធម៌ និងភាពរស់រវើក។
- អក្សរ ABA BANK ពណ៌សនៅចំកណ្តាល គឺជានិមិត្តសញ្ញានៃភាពស្មោះត្រង់ និងតម្លាភាពនៃហិរញ្ញវត្ថុរបស់ធនាគារ។

## ២.៣.ទីតាំងរបស់ធនាគារ ABA សាខាពោធិ៍សាត់

ធនាគារ ABA សាខាខេត្តពោធិ៍សាត់មានទីតាំងដូចខាងក្រោម៖

អាស័យដ្ឋាន ផ្ទះលេខ ៦៣៧ និង៦៣៨ ផ្លូវជាតិលេខ៥ ភូមិ ៣ ឃុំ ផ្ទះព្រៃ ខេត្តពោធិ៍សាត់។

លេខទូរស័ព្ទ៖ (៨៥៥) ៩៨ ៦៣០ ២៥៤/ ១២ ៥៦២ ៥៤៧

## ២.៤.ភាគទុនិក និងដៃគូ

### ២.៤.១.ភាគទុនិក

រចនាសម្ព័ន្ធភាគហ៊ុនបច្ចុប្បន្នរបស់ធនាគារ ABA

| ការចែករំលែក | ភាគទុនិក |
|---|---|
| NATIONAL BANK OF CANADA | ៩០% |
| លោក Dmair Karassayev | 10% |

ប្រភព៖ https://www.ababank.com/about-aba/about-us/

ធនាគារ ABA និង ធនាគារជាតិ កាណាដាបានប្រកាសពី កិច្ចព្រមព្រៀងដ៏សំខាន់សំរាប់ឧស្សាហកម្មធនាគារ នៅកម្ពុជា។ ក្រោយពីបានទទួលការអនុម័តយល់ស្របតាមនិតិវិធី និងបទបញ្ញត្តិតម្រូវនានា ធនាគារជាតិកាណាដា បានបង្កើនមូលធនរបស់ខ្លួនក្នុងធនាគារ ABA បន្ថែមទៀត តាមរយៈ " កិច្ចព្រមព្រៀងទិញភាគហ៊ុន " ពី ៤២% ដល់ ៩០% នៅថ្ងៃ ទី ៦ ខែមិថុនា ឆ្នាំ ២០១៦។

លោក Dmair Karassayev ជាម្ចាស់ភាគទុន ចំនួន១០% របស់ធនាគារ ABA។ លោកបានគ្រប់គ្រងអាជីវកម្មនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់តាំងពីឆ្នាំ ២០០៥ មកម្ល៉េះ។

### ២.៤.២.ដៃគូ

ធនាគារ ABA មានទំនាក់ទំនងសេវាកម្មជាមួយបណ្តាញធនាគារអន្តរជាតិល្បីៗជុំវិញពិភពលោក។ អាជីវកម្មដែលទាក់ទងនឹងការទូទាត់ និងការផ្ញើប្រាក់ផ្ទាល់ខ្លួនត្រូវបានធ្វើឡើងតាមរយៈគណនីទៅតាមប្រភេទរូបិយប័ណ្ណនីមួយៗ។

ខាងក្រោមនេះជាបញ្ជីឈ្មោះធនាគារដៃគូ និងធនាគារទីភ្នាក់ងាររបស់ធនាគារ ABA៖

- JP Morgan Chase Bank, សហរដ្ឋអាមេរិក
- Standard Chartered Bank, សហរដ្ឋអាមេរិក
- Standard Chartered Bank, ប្រទេសសិង្ហបុរី
- Woori Bank, ប្រទេសកូរ៉េខាងត្បូង
- Kookmin Bank, ប្រទេសកូរ៉េខាងត្បូង
- Korea Exchange Bank, ប្រទេសកូរ៉េខាងត្បូង
- DBS Bank, ប្រទេសសិង្ហបុរី
- Vietcom Bank, ប្រទេសវៀតណាម
- National Bank of Canada, ប្រទេសកាណាដា
- Commerzbank AG, ប្រទេសអាល្លឺម៉ង់
- Standard Chartered Bank, ប្រទេសអង់គ្លេស
- China Construction Bank Corporation, ប្រទេសចិន
- Standard Chartered Bank, ប្រទេសថៃ ។

## ២.៥.ទស្សនៈវិស័យ បេសកកម្ម និង គុណតម្លៃរបស់ធនាគារ ABA

### ២.៥.១.ទស្សនៈវិស័យ

ក្លាយជាធនាគារលំដាប់លេខមួយប្រចាំប្រទេស លើផ្នែកផ្តល់ផ្គត់សេវាធនាគារគួរជាទីទុកចិត្ត ងាយស្រួលប្រើប្រាស់ប្រកបដោយបច្ចេកវិទ្យាទំនើបបំផុត និងងាយស្រួលក្នុងការទទួលបាន។ យើងមានបំណងក្លាយជាធនាគារមួយដែរប្រជាជនកម្ពុជាជឿទុកចិត្តក្នុងការបំពេញតម្រូវការសេវាធនាគារផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្មរបស់គាត់ផងដែរ។

**២.៥.២.បេសកកម្ម**

ជួយដល់ប្រទេសកម្ពុជា អាជីវកម្មកម្ពុជា និងប្រជាជនកម្ពុជានៅក្នុងការជួយកសាងអនាគតកាន់តែទូលំទូលាយ និងត្រចេះត្រចង់តាមរយៈការផ្តល់សេវាកម្មធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ និងបច្ចេកវិទ្យាទំនើបបំផុតក្នុងផ្នែកធនាគារសម្រាប់អ្នកទាំងអស់គ្នា។ ក្នុងនាមជាធនាគារ ក្នុងស្រុក ពិតប្រាកដមួយយើងចាត់ទុកខ្លួនឯងថាជាដៃគូរដ៏ល្អមួយសម្រាប់សហគមន៍កម្ពុជា ក៏ដូចជាអាជីវកម្មឯកជន និងរូបវន្តបុគ្គលផងដែរ។ យើងនៅទៅនេះដើម្បីបម្រើសេវាជូនកម្ពុជា។

**២.៥.៣.គុណតម្លៃ**

➢ **សុចរិតភាព និងសេចក្តីគោរព**

នៅធនគារ ABA យើងចាត់ទុកចំណុចនេះជាការទទួលខុសត្រូវខ្ពស់របស់ធនាគារដែលត្រូវបម្រើសេវាជូនរាល់អតិថិជនប្រកបដោយភាពសុចរិត និងសេចក្តីគោរព។

➢ **ទំនុកចិត្ត និងភាពជាដៃគូ**

នៅធនាគារ ABA យើងនៅទីនេះដើម្បីជួយសម្រួល និងជាជំនួយការរបស់អតិថិជន។ យើងខិតខំធ្វើឲ្យខ្លួនក្លាយជាដៃគូដ៏ល្អដែលអតិថិជនរបស់យើងអាចជឿទុកចិត្តបាន។

➢ **គុណភាពនៃសេវាកម្ម**

នៅធនាគារ ABA យើងខិតខំស្វែងរកដំណោះស្រាយ ដើម្បីឆ្លើយតបចំពោះរាល់តម្រូវការធនាគារទាំងអស់។ យើងមានបំណងផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងបច្ចេកវិទ្យាទំនើបបំផុតសម្រាប់អតិថិជនកម្ពុជាទាំងអស់យើង ពោលគឺក្នុងតួនាទីជាជំនួយការគ្រប់គ្រងគណនីផ្ទាល់ខ្លួន ឬគណនីអាជីវកម្មរបស់អតិថិជន។

➢ **វិភាគទាន**

នៅធនាគារ ABA យើងមានបំណងផ្តល់វិភាគជាវិជ្ជមានដល់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីមួយដែលផ្តល់សារៈប្រយោជន៍សម្រាប់ការរស់នៅរបស់អតិថិជនយើង ក៏ដូចជាសម្រាប់អនាគតរបស់ប្រទេសទាំងមូលផងដែរ។

➢ **និរន្តរភាព និងកំណើន**

នៅធនាគារABA យើងតែងតែគិតគូរអំពីអនាគតរបស់ធនាគារយើង និងប្រជាជនកម្ពុជា ព្រមទាំងប្រទេសកម្ពុជាផងដែរ។ យើងសូមបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិករបស់យើង ក៏ដូចជាអតិថិជនរបស់យើងដែរ។ នេះជាវិធីសាស្ត្រមួយដែលអាចឲ្យយើងធានានូវកំណើនប្រកបដោយនិរន្តរភាពរបស់ធនាគារ។

➢ **ក្រមសីលធម៌ និងសុជីវធម៌**

នៅ ABA យើងអនុវត្តស្តង់ដារក្រមសីលធម៌ និងសុជីវធម៌រវាងគ្នានិងគ្នា ពោលគឺទាំងនៅក្នុង និងក្រៅធនាគារ។ គោលការណ៍ផ្ទាល់ខ្លួននេះហើយដែលបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃជាមួយអតិថិជន និងសហគមន៍ដែលយើងកំពុងផ្តល់សេវាជូន ក៏ដូចជាជាមួយបុគ្គលិកយើងផងដែរ។

## ២.៦.ផលិតផល និងសេវាកម្មរបស់ធនាគារ ABA

ធនាគារ ABA មានផលិតផលជាច្រើនដូចជា៖

### ២.៦.១.សេវាប្រាក់កម្ចី

❖ **ឥណទានអាជីវកម្មខ្នាតតូច**

ប្រសិនបើលោកអ្នកជាម្ចាស់អាជីវកម្មហើយត្រូវការពង្រីកអាជីវកម្ម លោកអ្នកអាចដាក់ពាក្យស្នើរសុំអាជីវកម្មខ្នាតតូចរបស់ធនាគារបានដោយលោកអ្នកអាចខ្ចីប្រាក់បានរហូតដក់ ៧០.០០០០ដោយអត្រាការប្រាក់ទាបក្នុងរយៈពេល ៧ឆ្នាំ ។

❖ **ឥណទានសាជីវកម្ម**

ឥណទានប្រភេទនេះបង្កើតឡើងដើម្បីឆ្លើយតបតាមតម្រូវការប្រតិបត្តការ និងតម្រូវការផ្សេងៗជាច្រើនទៀត ។

❖ **ឥណទានអាជីវកម្ម**

ក្នុងគោលបំណងឆ្លើយតបទៅនិងតម្រូវការហិរញ្ញប្បទានសម្រាប់ទុនបង្វិលតម្រូវការប្រតិបត្តិការ តម្រូវការហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ឥណទានអាជីវកម្មធនាគារ ABA ជាប្រភពជំនួញធនធានដ៏ពិសេសសម្រាប់ការពង្រីក និង អភិវឌ្ឍអាជីវកម្មថ្មីរបស់លោកអ្នក។

### ២.៦.២.សេវាកម្មផ្ទេរប្រាក់

❖ **សេវាកម្មផ្ទេរប្រាក់ក្នុងស្រុក**

មូលដ្ឋាននៃការផ្ទេរទឹកប្រាក់រវាងធនាគារ ABA និងធនាគារដទៃទៀតនៅកម្ពុជា។ យើងមានកិច្ចសហការជាដៃគូរជាមួយធនាគារទាំងអស់នៅកម្ពុជា ដូច្នេះទឹកប្រាក់របស់លោកអ្នកនឹងត្រូវផ្ទេរក្នុងរយៈពេលមួយថ្ងៃប៉ុណ្ណោះ។

❖ **សេវាផ្ទេរប្រាក់ទូគមនាគមន៍អន្តរជាតិតាមប្រព័ន្ធ SWIFT**

ជាសេវាផ្ទេរប្រាក់ក្រៅប្រទេសដ៏ឆាប់រហ័សសម្រាប់ឯកត្តជន ឬក្រុមហ៊ុនសាជីវកម្មតាមរយៈបណ្តាញធនាគារអន្តរការីរបស់ ABA។ ជាមួយគ្នានិងការផ្ទេរប្រាក់ទូគមនាគមន៍ សាច់ប្រាក់របស់លោកអ្នកនឹងត្រូវបាន

ផ្ទេរដោយផ្ទាល់ទៅក្នុងគណនីរបស់អ្នកទទួលយ៉ាងឆាប់រហ័ស និងមានសុវត្ថិភាពបំផុត។ លេខកូដធនាគារ ABA តាមរយៈប្រព័ន្ធ SWIFT គឺ ABAAKHPP។

❖ **សេវាផ្ទេរប្រាក់ RemitEX**

RemitEX ជាសេវាផ្ទេរប្រាក់ដែនមានអត្រាប្តូរប្រាក់ថេរសម្រាប់ប្រទេសមួយចំនួន។ សេវានោះមិនគិតថ្លៃលើការបញ្ជូនទឹកប្រាក់ ហើយអ្នកអាចរីករាយជាមួយអត្រាប្តូរប្រាក់ថេរ សម្រាប់រូបិយប័ណ្ណផ្ញើរ ខុសពីរូបិយប័ណ្ណទទួល។

❖ **សេវាផ្ទេរប្រាក់អន្តរជាតិភ្លាមៗ**

នៅធនាគារABA យើងក៏មានផ្តល់នូវសេវាផ្ទេរប្រាក់បន្ទាន់ភ្លាមៗផងដែរ។ លោកអ្នកអាចផ្ញើរប្រាក់ទៅកាន់អ្នកជាទីស្រឡាញ់របស់ខ្លួនតាមរយៈប្រព័ន្ធសេវា MoneyGram និងIME ដែលមាននៅតាមសាខាណាមួយរបស់ធនាគារABA។

ដោយមានបណ្តាញភ្នាក់ងារផ្ទេរប្រាក់ ដ៏ទូលំទូលាយចំនួន២៥៦០០០កន្លែងនៅជុំវិញពិភពលោក សេវា MoneyGram ផ្តល់នៅមធ្យោបាយសុវត្ថិភាពមួយក្នុងការផ្ញើរ និងទទួលប្រាក់នៅទូទាំងពិភពលោក។ ជាមួយនិងសេវាផ្ទេរប្រាក់IME ដែលមាននៅតាមសាខាធនាគារABA ទឹកប្រាក់លោកអ្នកត្រូវបានផ្ទេរយ៉ាងឆាប់រហ័សភ្លាមៗ ហើយសាច់ប្រាក់និងដល់ដៃអ្នកទទួលទាន់ពេលវេលា ដោយមិនគិតថ្លៃសេវាពេលទទួលឡើយ។ សេវាផ្ទេរប្រាក់ IME បានបង្កើតបណ្តាញធនាគារដៃគូអន្តរការីរបស់ខ្លួនជាង១០០០០០០គ្រឹះស្ថាននៅទូទាំងពិភពលោក។

### ២.៦.៣.សេវាស្វ័យធនាគារ

❖ **សេវាធនាគារតាមទូរស័ព្ទដៃ**

ABA Mobile គឺជាកម្មវិធីទូរស័ព្ទដៃដំបូងគេនៅកម្ពុជា ដែលផ្តល់សេវាធនាគារពេញលេញនិងមានអ្នកប្រើប្រាស់សកម្មចំនួន ១០០០០០នាក់ ជាមួយប្រតិបត្តិការ ៣០០០០០០ក្នុងមួយឆ្នាំ។ វា គឺជាឧបករណ៍ហិរញ្ញវត្ថុ ដ៏សមស្របបំផុតសម្រាប់អ្នកដែរត្រូវការគ្រប់គ្រង ឬចាត់ចែងប្រាក់ ឬគណនីគ្រប់ពេលវេលា ២៤ម៉ោង។ អ្នកអាចពិនិត្យសមតុល្យ បើកគណនីបញ្ញើកាលកំណត់ បើកកាតនិម្មិត បង់វិក័យបត្របានភ្លាមៗដោយមិនគិតថ្លៃសេវា រួមទាំងរួមទាំងមុខងារពិសេសៗជាច្រើនទៀត។ កម្មវិធីអាចទាញយកបានដោយឥតគិតថ្លៃនៅ Google Play និង Apple App Store។

❖ **ម៉ាស៊ីនអេធីអឹម**

រហូតមកដល់បច្ចុប្បន្ននេះធនាគារ ABA មានម៉ាស៊ីន ABA ច្រើនជាង ២០០ នៅទូទាំងប្រទេសហើយចំនួននេះកំពុងតែបន្តឡើងយ៉ាងឆាប់រហ័ស។ វាមិនគ្រាន់តែជាម៉ាស៊ីនអេធីអឹម សម្រាប់ដកប្រាក់ប៉ុណ្ណោះទេ តែ

លោកអ្នកក៏អាចពិនិត្យមើលសមតុល្យក្នុងគណនីលោកអ្នក ការផ្ទេរប្រាក់ពីធនាគារមួយទៅធនាគារមួយទៀតរបស់លោកអ្នក បង់វិក័យផ្សេងៗដែលរួមមានការបញ្ចូលប្រាក់តាមទូរស័ព្ទ បង់ថ្លៃសេវាអ៊ីនធឺណិត និង សេវាសាធារណៈជាច្រើនទៀត។

❖ **ធនាគារតាមអ៊ីនធឺណិត**

អាចប្រើប្រាស់បានគ្រប់ពេល ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្ដាហ៍ តាមរយៈសេវាធនាគារតាមអ៊ីនធឺណិតក្នុងការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុចាប់ពីការពិនិត្យរបាយការណ៍គណនីរហូតដល់ការធ្វើការទូទាត់ឬផ្ទេរប្រាក់។ វាងាយស្រួលក្នុងការបង្កើត និងប្រើប្រាស់ ហើយអាចអោយលោកអ្នកប្រតិបត្តិការជាប្រចាំថ្ងៃដោយមិនចាំទៅសាខាណាមួយឡើយ។

❖ **សេវា Cash-in Kiosk**

Cash-in Kiosk ជួយអតិថិជនរបស់ធនាគារ ABA ក្នុងការដាក់ប្រាក់បញ្ញើក្នុងគណនីណាមួយរបស់ធនាគារABA ឬទូទាត់សេវាកម្មផ្សេងៗទៅកាន់ក្រុមហ៊ុនផ្គត់ផ្គង់នានា។ រាល់ប្រតិបត្តិការទាំងអស់នឹងបង្ហាញភ្លាមៗលើគណនីអតិថិជននូវឈ្មោះក្រុមហ៊ុនផ្ដល់សេវាកម្មនីមួយៗ ឬគណនីរបស់អនាគារ ABA។ Kiosk ប្រតិបត្តិការពេញ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្ដាហ៍ ព្រមទាំងអនុញ្ញាតឲ្យលោកអ្នកអាចបញ្ចូលទឹកប្រាក់ក្នុងគណនីធនាគារ ABA ដោយមិនចាំបាច់រងចាំធ្វើប្រតិបត្តិការក្នុងម៉ោងធ្វើការរបស់ធនាគារឡើយ។

❖ **សេវាធនាគារតាមអ៊ីនធឺណិតសម្រាប់សាជីវកម្ម**

សេវាកម្មធនាគារ ABA តាមអ៊ីនធឺណិតសម្រាប់សារជីវកម្មអាចអោយអ្នកប្រើប្រាស់ គណនីអាជីវកម្មតាមអនឡាញប្រកបដោយសុវត្ថិភាព និងងាយស្រួល។ អ្នកអាចប្រើប្រាសើសេវានេះបានគ្រប់ពេលដើម្បីឆ្លើយតបនឹងតម្រូវការអាជីវកម្មដូចជា៖ អនុញ្ញាតនិងធ្វើការទូទាត់ជូនអ្នកផ្គត់ផ្គង់ ឬបុគ្គលិក ត្រួតពិនិត្យសមតុល្យគណនីនិងប្រតិបត្តិការថ្មីៗ ផ្ទេរប្រាក់ពីគណនីមួយទៅគណនីមួយទៀតនៅក្នុងធនាគារតែមួយ ឬធនាគារផ្សេង ផ្ទេរទៅក្រៅប្រទេសព្រមទាំងសេវាផ្សេងជាច្រើនទៀត។

❖ **សេវាដកប្រាក់ដោយមិនចាំបាច់ប្រើកាត**

E-Cash គឺជាសេវាដកប្រាក់ពីម៉ាស៊ីនអេធីអឹមដោយមិនបាច់ប្រើកាត ហើយបានដាក់អោយប្រើប្រាស់ដោយធនាគារ ABA ក្នុងឆ្នាំ២០១៥។ តាមរយៈសេវាកម្មនេះអាចឲ្យអ្នកដែលមិនមានគណនីជាមួយABA អាចដកសាច់ប្រាក់ពីម៉ាស៊ីនអេធីអឹមណាមួយរបស់ ABA ដោយមិនចាំបាច់មានកាត។ អ្នកត្រូវការត្រឹមតែលេខកូដសុវត្ថិភាពដេលផ្ដល់ពីអ្នកផ្ញើរជាអតិថិជនរបស់ ABA ប៉ុណ្ណោះ។

### ២.៦.៤ សេវាទូទាត់អនឡាញ PayWay

PayWay គឺជាមធ្យោបាយទូទាត់ប្រាក់ដ៏ទំនើបឈានមុខរបស់ABA ដែលជួយឲ្យអ្នកលក់ដូរអនឡាញក្នុងស្រុក ទទួលការទូទាត់ប្រាក់បានភ្លាមៗ និងងាយស្រួលបំផុតតាមរយៈអ៊ីវ៉ាឡេត និងកាតទូទាត់ជាច្រើនប្រភេទ ។

PayWay គឺជាដំណោះស្រាយដ៏ប្រសើរបំផុតសម្រាប់អ្នកធ្វើអាជីវកម្មលើសេវាកម្មដូចជាៈ លក់សំបុត្រយន្តហោះ សេវាកម្មធ្វើដំណើរតាមអនឡាញ វិទ្យាស្ថានអប់រំ ហាងទំនិញអនឡាញ រោងភាពយន្ត សេវាដឹកជញ្ជូនអាហារ សណ្ឋាគារ ភោជនីយដ្ឋាន និងសេវាកម្មជាច្រើនទៀត ។

### ២.៦.៥.សេវាបើកប្រាក់បៀវត្សរ៍

សេវាបើកប្រាក់បៀវត្សរ៍របស់ធនាគារ ABA ផ្តល់ឱកាសប្រសើរបំផុតសំរាប់ជួយសម្រួលអាជីវកម្មដែលមានបុគ្គលិកច្រើន ដោយអាចកាត់បន្ថយដំណើរឯកសារ និងបង្កើនសុវត្ថិភាព។ ដូច្នេះលោកអ្នកមិនចាំបាច់ដកសាច់ប្រាក់ពីគណនីសារជីវកម្ម ឬ ចេញមូប្បទានបត្រទៀតឡើយ។

ចំពោះសេវាកម្មនេះ ធនាគារ ABA នឹងចេញប័ណ្ណ ATM ដោយឥតគិតថ្លៃជូនបុគ្គលិកពួកគាត់ ដើម្បីឲ្យពួកគេអាចប្រើប្រាស់មូនិធិរបស់ខ្លួនបានភ្លាមក្នុងរយៈពេល ២៤ ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍តាមរយៈបណ្តាញម៉ាស៊ីនអេធីធីម របស់ធនាគារ ABA។

### ២.៦.៦.កាតទូទាត់

- **កាតឥណពន្ធ**

កាតឥណពន្ធ VISA, Mastercard និង China UnionPay ពីធនាគារ ABA អាចប្រើប្រាស់ជាមួយម៉ាស៊ីនអេធីអឹមទាំងក្នុង និងក្រៅប្រទេស និងសម្រាប់ការទិញទំនិញ និងសេវាកម្មផ្សេងៗប្រចាំថ្ងៃផងដែរ។ កាត VISA និង Mastercard អន្តរជាតិក៏អាចប្រើប្រាស់បានលើ PayPal សម្រាប់រាល់ការទូទាត់លើបណ្តាញអ៊ីនធឺណិតផ្សេងៗបានផងដែរ។

- **កាតឥណទាន**

ធនាគារ ABA ចេញកាតឥណទានអន្តរជាតិ Mastercard និង VISA ដែលត្រូវបានទទួលស្គាល់ទាំងពិភពលោក។ កាតឥណទានផ្តល់នូវអាទិភាពដ៏សំខាន់ក្នុងការប្រើប្រាស់ទឹកប្រាក់របស់ធនាគារ នៅពេលដែលលោកអ្នកត្រូវការបន្ទាន់ បន្ទាប់ពីម៉ាស៊ីនឆូតកាតពិនិត្យឃើញថាកាតមានទឹកប្រាក់អាចទូទាត់បាន។

# ជំពូកទី៣

# ការគ្រប់គ្រងឥណទានគេហដ្ឋាន

## ៣.១.លក្ខណៈទូទៅនៃឥណទានគេហដ្ឋាន

### ៣.១.១.និយមន័យ

ឥណទានគេហដ្ឋានគឺជាផលិតផលមួយប្រភេទក្នុងចំណោមផលិតផលជាច្រើនទៀតរបស់ធនាគារ ABA ដែលត្រូវបង្កើតឡើងសម្រាប់បំពេញនូវតម្រូវការរបស់សារធារណៈជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទិញយកទៅធ្វើអាជីវកម្មផ្សេង។

### ៣.១.២.គោលបំណង

គោលបំណងតែមួយគត់ដែលធនាគារ ABA បង្កើតឲ្យមាននូវឥណទានគេហដ្ឋាន គឺដើម្បីបំពេញនូវតម្រូវការរបស់អតិថិជនក្នុងការទិញលំនៅដ្ឋានជាកម្មសិទ្ធផ្ទាល់ខ្លួនសម្រាប់ប្រកបរបរអាជីវកម្មផ្សេងៗ។

### ៣.១.៣.អត្ថប្រយោជន៍

#### ៣.១.៣.១.សម្រាប់ធនាគារ

- ទទួលបានប្រាក់ចំណូលបន្ថែម និងកម្រៃសេវាផ្សេងៗ
- ដើម្បីនិរន្តរភាពប្រតិបត្តិការរបស់ធនាគារ
- ធនាគារមានទំនុកចិត្តក្នុងការប្រកួតប្រជែង និងទាក់ទាញអតិថិជន។

#### ៣.១.៣.២.សម្រាប់អតិថិជន

- មានឱកាសក្នុងការទទួលបានគេហដ្ឋានដែលជាកម្មសិទ្ធផ្ទាល់
- ទទួលបានកម្ចីក្នុងរយៈពេលវែងក្នុងការទិញ
- បង្កើនកម្រិតជីវភាពប្រជាជននៅពេលពួកគេទិញគេហដ្ឋានសម្រាប់ធ្វើអាជីវកម្ម។

#### ៣.១.៣.៣.សម្រាប់សង្គម

- ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន
- ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៣.១.៤.ទីផ្សារគោលដៅ

ទីផ្សារគោលដៅនៃឥណទានគេហដ្ឋាន រួមមានរូបវន្តបុគ្គលដែលមានប្រាក់ចំណូលពីប្រាក់បៀវត្ស និងបុគ្គលដែលមានអាជីវកម្មផ្ទាល់ខ្លួន ជាពិសេសបុគ្គលនោះត្រូវជាជនជាតិខ្មែរ។

### ៣.១.៥.ផលិតផលឥណទានគេហដ្ឋាន

#### ៣.១.៥.១.ទំហំនៃការផ្តល់ឥណទាន

ធនាគារ ABA អាចផ្តល់ជូននៅឥណទានគេហដ្ឋានដល់អតិថិជន ពី ៦០% ទៅ ៧០% នៃតម្លៃគេហដ្ឋាន ដែលអតិថិជនបម្រុងនឹងទិញ។ តែម្យ៉ាងវិញទៀត ធនាគារក៏អាចផ្តល់ជូនអតិថិជននូវឥណទាន១០០% នៃតម្លៃ គេហដ្ឋានដែលអតិថិជនបម្រុងនឹងទិញផងដែរ ប្រសិនបើភ្នាក់ងារឥណទានយល់ថា អតិថិជននោះពិតជាមាន លក្ខណៈគ្រប់គ្រាន់ក្នុងការទទួលទាំងស្រុង ឬអាចជាអតិថិជនចាស់ដែលមានប្រវត្តិ (Credit) ល្អជាមួយធនាគារ ក៏អាចជាផ្នែកមួយដើម្បីលើកទឹកចិត្តដល់អតិថិជន និងអាចទាក់ទាញអតិថិជនបានថែមទៀតផង។

- **ទំហំឥណទានអប្បបរមា៖** អាចខ្ចីបានចាប់ពី ៥,០០០ដុល្លារអាមេរិច ទៅ ១៥,០០០ដុល្លារអាមេរិច។
- **ទំហំឥណទានអតិបរមា៖** អាចខ្ចីបានចាប់ពី ១៥០,០០១ដុល្លារអាមេរិចឡើងទៅ។
- ➢ សម្រាប់ប្លង់រឹង១៥០,០០០ដុល្លាអាមេរិចឡើង អាស្រ័យទៅតាមទ្រព្យមានតម្លៃខ្ពស់ឬក៏ទាបទៅតាម ជាក់ស្តែង ហើយធនាគារអាចផ្តល់កម្ចីបាន ៧០% នៃទ្រព្យដែលអតិថិជន ដាក់បញ្ចាំនៅធនាគារ។
- ➢ សម្រាប់ប្លង់ទន់ អាចខ្ចីបាន ៧០% នៃទ្រព្យសម្រាប់ដាក់បញ្ចាំនៅធនាគារដូចគ្នា។

#### ៣.១.៥.២.រយៈពេលឥណទាន

រយៈពេលនៃឥណទានគេហដ្ឋាន គឺមានរយៈពេល ១០ ឆ្នាំដែលធនាគារអាចផ្តល់ឥណទានគេហដ្ឋាន។

#### ៣.១.៥.៣.អត្រាការប្រាក់

អត្រាការប្រាក់ឥណទានគេហដ្ឋានគឺពី ១៣% ដល់ ១៦% ក្នុងមួយឆ្នាំដែលស្មើរនឹង ១.០៨% ដល់ ១.៣៣%ក្នុងមួយខែ។

#### ៣.១.៥.៤.វិធីសាស្ត្រនៃការសងត្រឡប់

វីធីសាស្ត្រនៃការសងត្រឡប់នៅក្នុងធនាគារ ABA មាន ២ ប្រភេទគឺ៖

**ក. បង់រលស់ប្រចាំខែថេរទាំងដើមទាំងការ៖** គឺជារបៀបសងប្រាក់មួយប្រភេទដែលអតិថិជនបង់ចំនួន ទឹកប្រាក់ថេរប្រចាំគ្រាដែលក្នុងនោះរួមប្រាក់ដើមដែលត្រូវបង់រំលស់ និងការប្រាក់ដែលត្រូវបង់។

ឧទាហរណ៍ៈ លោក សំបូរ បានខ្ចីប្រាក់ពីធនាគារចំនួន $១០០០០០ ក្នុងនោះអត្រាការប្រាក់១៣%ក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំ។ ចូរធ្វើតារាងបង់រលស់ប្រាក់ដើមថេរ និងការប្រាក់ប្រចាំខែ

**ដំណោះស្រាយ**

ដោយៈ (i) អត្រាការប្រាក់ ១៣%ក្នុងមួយឆ្នាំ =1.083333 ក្នុងមួយខែ

(t) រយៈពេល៥ឆ្នាំ (60ខែ)

(P) ប្រាក់ដែលខ្ចី 100,000$

- រកប្រាក់ដើមដែលត្រូវបង់ក្នុងខែទី១

តាមរូបមន្ត $C=\frac{P\times i}{1-(1+i)^{-t}}$

$$C = \frac{100000\times 0.01083333}{1-(1+0.01083333)^{-60}} = 2275.31\$$$

- រកការប្រាក់ត្រូវបង់ក្នុងខែទី1

តាមរូបមន្ត I= (P × r)

I= (100,000×0.01083333) = 1083.33$

⇒ ប្រាក់ដើមដែលត្រូវបង់ក្នុងខែទី១ = 2275.31-1083.33 = 1191.97$

- រកការប្រាក់បង់ក្នុងខែទី2

I= (100,000-1191.97) ×0.01083333) = 1070.42$

**តារាងទី១**

| ចំនួនខែ | អត្រាការប្រាក់ | ប្រាក់ដើម | សរុបប្រាក់ត្រូវសង | សមតុល្យ |
|---|---|---|---|---|
| | | | | 100,000.00$ |
| ខែទី1 | 1,083.33$ | 1,191.97$ | 2,275.31$ | 98,808.03$ |
| ខែទី2 | 1,070.42$ | 1,204.89$ | 2,275.31$ | 97,808.03$ |
| ខែទី3 | 1,057.37$ | 1,21.94$ | 2,275.31$ | 96,385.20$ |
| . | | | | |
| . | | | | |
| . | | | | |
| ខែទី59 | 48.51$ | 2,226.80$ | 2,275.31$ | 2250.92$ |
| ខែទី60 | 24.38$ | 2,250.92$ | 2275.31$ | (0.00)$ |

ខ. **ការបង់រំលស់ប្រចាំខែជាមួយប្រាក់ដើមថេរ៖** គឺជារបៀបសងប្រាក់មួយប្រភេទដែលបង្កើតឡើងសម្រាប់ផ្តល់ជូនអតិថិជនដែលជាពាណិជ្ជករ អាជីករ និយោជិកជាដើមដែលពួកគាត់មានប្រាក់ចំណូលទៀងទាត់ប្រចាំខែ និងត្រូវការទុនដើម្បីប្រើប្រាស់។ ការសងត្រឡប់ប្រភេទនេះអតិថិជនត្រូវបង់ប្រាក់ដើមថេរជារៀងរាល់គ្រា ដែលចំនួនទឹកប្រាក់ដែលបង់សរុបម្តងៗស្មើនឹងប្រាក់ដើមដែលត្រូវរំលស់បូកនឹងការប្រាក់។

**ដំណោះស្រាយ**

ដោយៈ (i) អត្រាការប្រាក់13%ក្នុងមួយឆ្នាំ

(t) រយៈពេលខ្ចី5ឆ្នាំ (60ខែ)

(P) ប្រាក់ដែលខ្ចី 100,000$

- រកប្រាក់ដើមដែលត្រូវបង់ក្នុងខែទី១

ប្រាក់ដើមដែលត្រូវបង់ $= \frac{\text{ប្រាក់ជំពាក់សរុប}}{\text{រយៈពេលខ្ចី}}$

$= \frac{100000}{60}$ =1666.67$

- រកការប្រាក់ត្រូវបង់ក្នុងខែទី១

តាមរូបមន្ត I = (P×i)

I = (100,000×0.01083333) =1083.33$

- រកការប្រាក់ត្រូវបង់ក្នុងខែទី២

I = (100,000-1666.67) × 0.01083333 =1065.28$

- រកប្រាក់ដែលត្រូវក្នុងខែទី១

ប្រាក់ដែលត្រូវបង់សរុប = ប្រាក់ដើមដែលរំលស់+ការប្រាក់ខែទី១

= 1666.67+1083.33 =2750$

- រកប្រាក់ដែលត្រូវបង់ក្នុងខែទី២

=1666.67+ 1065.28=2731.94$

**តារាងទី២**

| ចំនួនខែ | អត្រាការប្រាក់ | ប្រាក់ដើម | សរុបប្រាក់ត្រូវសង | សមតុល្យ |
|---|---|---|---|---|
| | | | | 100,000.00$ |
| ខែទី1 | 1,083.33$ | 1,666.67$ | 2,750.00$ | 98,333.33$ |
| ខែទី2 | 1,065.28 | 1,666.67$ | 2,731.94$ | 96,666.67$ |
| ខែទី3 | 1,047.22$ | 1,666.67$ | 2,713.89$ | 95,000.00$ |
| . | | | | |
| . | | | | |
| . | | | | |
| ខែទី59 | 36.11$ | 1,666.67$ | 1,702.78$ | 1,666.67$ |
| ខែទី60 | 18.06$ | 1,666.67$ | 1.684.72$ | (0.00)$ |

## ៣.២.លក្ខខណ្ឌតម្រូវសម្រាប់ឥណទានគេហដ្ឋាន

### ៣.២.១.លក្ខខណ្ឌសម្រាប់អ្នកខ្ចី

ដើម្បីទទួលបានឥណទានគេហដ្ឋាន អ្នកខ្ចីត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ជាប្រជាជនកម្ពុជា និងមានលំនៅដ្ឋាននៅប្រទេសកម្ពុជា
- មិនមានប្រវិត្តធ្លាប់ខ្ចីលុយពីធនាគារផ្សេងៗ
- មិនមានប្រវិត្តធ្លាប់ខូចឈ្មោះជាមួយធនាគារដទៃ
- ចំពោះអ្នកមានការងារធ្វើត្រូវមានលិខិតបញ្ជាក់ប្រាក់ខែ ឬ របាយការណ៍ជាមួយធនាគារ ដែលបើកប្រាក់ខែតាមធនាគារ
- ចំពោះអ្នកមានមុខរបររកស៊ីត្រូវមានវិក័យបត្រទិញចូល និង លក់ចេញ
- ត្រូវមានមុខរបរណាដែរស្របច្បាប់។

### ៣.២.២.ការលើកលែង/ព្រំដែនក្នុងការផ្តល់ឥណទាន

ទោះបីជាឥណទានត្រូវបានផ្តល់ឲ្យដល់អតិថិជនដែលដែលតម្រូវឲ្យមានមុខរបរ និង ប្រាក់ចំណូលពីការងាផ្សេងៗក៏ដោយ ប៉ុន្តែក៏មានមុខរបរមួយចំនួនដែលត្រូវបានជៀសវាងក្នុងការផ្តល់ឥណទានផងដែរ។ មុខរបរ និង លក្ខខណ្ឌដែលត្រូវជៀសវាងមានដូចជា៖

- សកម្មភាពខុសច្បាស់ និង មិនស្របច្បាប់ទាំងឡាយណា ដែលស្ថិតនៅក្រោមការហាមឃាត់នៃច្បាប់ព្រះរាជាណាចក្រកម្ពុជា មានដូចជា៖
  - ➢ ការលេងល្បែងស៊ីសង
  - ➢ ការជួញដូរគ្រឿនញៀន។
- ជាបន្ថែម ចំនុចខាងក្រោមក៏ជៀសវាងក្នុងការផ្តល់ឥណទានផងដែរ ដូចជា៖
  - ➢ ជនដែលមិនមានសិទ្ធធ្វើការងារស្របច្បាប់តាមច្បាប់កំណត់
  - ➢ ជនពិការសតិ
  - ➢ ជនញៀនគ្រឿងស្រវឹង
  - ➢ ជនញៀនគ្រឿងញៀន។

### ៣.២.៣.ទ្រព្យធានា

ឥណទានគេហដ្ឋានបញ្ចេញដោយធនាគារ ABA ត្រូវមានទ្រព្យធានាដូចខាងក្រោម៖

- ប្រភេទទ្រព្យសម្បត្តិដែលទទួលជាទ្រព្យបញ្ចាំ៖ ទ្រព្យសម្បត្តិលំនៅដ្ឋាន ដែលកំពុងខ្ចីប្រាក់សម្រាប់ទិញទ្រព្យផ្ទាល់ខ្លួន និងអចលនទ្រព្យដែលមានប្លង់រឹង

- តម្លៃទ្រព្យសម្បត្តិធានាទាំងអស់ត្រូវចុះវាយតម្លៃវាយតម្លៃដោយមន្ត្រីឥណទាន និង ត្រូវចុះត្រួតពិនិត្យឡើងវិញដោយប្រធានឥណទាន។

**៣.២.៤.អ្នកធានា**

គ្រប់ឥណទានទាំងអស់ត្រូវមានអ្នកខ្ចី និងអ្នករួមខ្ចីយ៉ាងតិចម្នាក់ ក្នុងនោះផងដែរឥណទានគេហដ្ឋានក៏ដូចគ្នា គឺត្រូវមានអ្នកខ្ចី និងអ្នករួមខ្ចីយ៉ាងតិចម្នាក់។ អ្នករួមខ្ចី គឺជាប្ដីប្រពន្ធដែលបានរៀបការ និងឪពុក ម្ដាយ បងប្អូនបង្កើត កូនចៅមិនទាន់រៀបការ លែងលះ ពោះម៉ាយ មេម៉ាយជាដើម។ ក្នុងបរិបទដែលមិនមានសមាជិកគ្រួសារសម្រាប់ចូលរួមខ្ចី អាចបុគ្គលភាគីខាងក្រៅទី៣ឈរជាអ្នកធានាឥណទាន។ ដោយអ្នករួមខ្ចីឥណទានត្រូវយកទ្រព្យ ( ប្លង់ដី )យកមកបញ្ចាំនៅធនាគារជំនួសឲ្យអ្នកខ្ចី ដោយមានការផ្ដិតមេដៃលើកិច្ចសន្យាខ្ចីផងដែរ។

**៣.២.៥.ការរៀបចំឯកសារ**

**ការរៀបចំឯកសារមុនពេលអនុម័តឥណទាន**

- ពាក្យស្នើសុំខ្ចីប្រាក់
- ឯកសារកំណត់អត្តសញ្ញាណកម្មមួយក្នុងចំណោមខាងក្រោមៈ
    1. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
    2. សៀវភៅគ្រួសារ
    3. សៀវភៅស្នាក់នៅ
    4. លិខិតឆ្លងដែន
    5. សំបុត្រកំណើត
    6. លិខិតបញ្ជាក់ដូចជាៈ
        - ឯកសារភស្តុតាងប្រាក់ចំណេញ
        - គម្រោងជំនួញ/អាជីវកម្ម
        - ឯកសារទ្រព្យបញ្ចាំថតចម្លង

**ឯកសារក្រោយពេលអនុម័ត**

- កិច្ចសន្យាដាក់បញ្ចាំ
- កិច្ចសន្យាខ្ចីប្រាក់
- បង្កាន់ដៃទទួលប្រាក់
- ទទួលតារាងកាលវិភាគសងប្រាក់។

**៣.២.៦.ការខកខានសង និងការផាកពិន័យ**

### ៣.២.៦.១.ការខកខានសង

ឥណទានត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យា កាលណាដល់ពេលវេលាសងហើយ តែអ្នកខ្ចីមិនបានសងទាន់ពេលវេលាដូចបានចែងក្នុងកិច្ចសន្យា និង តាមតារាងកាលវិភាគសងប្រាក់។ រយៈពេលខកខានសងប្រាក់ គឺជាចំនួនថ្ងៃដែលខកខានមិនបានសងតាមតារាងកិច្ចសន្យារាប់ចាប់ពីថ្ងៃយឺតដំបូង។

### ៣.២.៦.២.ការផាកពិន័យ

ប្រាក់ផាកពិន័យត្រូវបានផាកតាមរយៈពេល និងសមតុល្យជាក់ស្តែងដែលនៅជំពាក់ ឬមិនទាន់សងជូនធនាគារដោយមានកាលកំណត់។ ប្រសិនបើអតិថិជនមានការខកខានសង ឬយឺតយ៉ាវក្នុងការសង គឺធនាគារគិតការប្រាក់ប្រចាំថ្ងៃបន្ថែមពីលើការប្រាក់ដែលអតិថិជនត្រូវបង់។ ឧទាហរណ៍ៈ មានអតិថិជនម្នាក់ខ្ចីប្រាក់ចំនួន ១០០០០$ ដោយគិតអត្រាការប្រាក់ ០.៨៨$/ខែ នោះការប្រាក់ដែលអតិថិជនត្រូវបង់ក្នុងខែនោះគឺ ៨៨$ តែប្រសិនបើអតិថិជន មានការយឺតយ៉ាវក្នុងការបង់ការប្រាក់ចំនួន១០ថ្ងៃ នោះធនាគារនឹងគិតការប្រាក់ប្រចាំថ្ងៃ។ ដូចនេះ អតិថិជនត្រូវបង់ការប្រាក់បន្ថែមទៀតចំនួន២៩.៣៣$ (បានមកពី ៨៨៖៣០x១០ ) ពីលើការប្រាក់ ៨៨$។ ដូចនេះការប្រាក់សរុបដែលអតិថិជនត្រូវបង់ជូនធនាគារគឺ ១១៧.៣៣$ ( ៨៨$+២៩.៣៣$ )។

### ៣.២.៦.៣.ការផាកពិន័យចំពោះការបង់ផ្តាច់មុនកាលកំណត់

ការផាកពិន័យចំពោះការបង់ផ្តាច់មុនកាលកំណត់របស់ធនាគារ ABA មានពីរករណីដូចខាងក្រោម៖

1. ប្រសិនបើអតិថិជន យកលុយដែលបានមកពីការលក់ដី លក់ឡាន ឬ លក់ទ្រព្យផ្សេងៗរបស់គាត់មកធ្វើការបង់ផ្តាច់មុនកាលកំណត់ ហើយអតិថិជនមានក្រដាសស្នាម ឬឯកសារយោងដែលគាត់បានមកពីលក់ទ្រព្យរបស់ទាំងនោះមកដាក់អោយធនាគារ នោះធនាគារនឹងធ្វើការលើកលែងការផាកពិន័យ ឬផាកពិន័យ១% ឬ២% នៃប្រាក់ដើមនៅសល់ ទៅតាមការចរចាគ្នារវាងធនាគារ និងអតិថិជន។
2. តែប្រសិនបើជាអតិថិជន យកលុយដែលបានមកពីការខ្ចីពីស្ថាប័នផ្សេង មកធ្វើការបង់ផ្តាច់មុនកាលកំណត់ នោះធនាគារនឹងធ្វើការផាកពិន័យ៣% នៃប្រាក់ដើមនៅសល់ ទៅលើអតិថិជននោះ។

## ៣.៣.នីតិវិធីក្នុងការផ្តល់ឥណទានគេហដ្ឋាន

នីតិវិធីក្នុងការផ្តល់ឥណទានគេហដ្ឋាន មាន៥ដំណាក់កាលដូចខាងក្រោម៖

- **ដំណាក់កាលទី១: ការដាក់ពាក្យស្នើសុំឥណទាន**
  - អតិថិជនអាចទៅកាន់សាខាណាមួយរបស់ធនាគារ ABA ហើយជួបជាមួយអ្នកគ្រប់គ្រងអតិថិជនរបស់ធនាគារដែលនឹងណែនាំអំពីនីតិវិធីក្នុងការដាក់ពាក្យ។

- ភ្នាក់ងារបម្រើអតិថិជនធ្វើការពន្យល់អំពីឥណទានគេហដ្ឋាន ( ទំហំឥណទាន, របៀបសង, រយៈពេល, អត្រាការប្រាក់ និងប្រាក់ចំណាយផ្សេងៗ ) ទៅកាន់អតិថិជន និងអ្នករួមខ្ចី ( អ្នកធានា )។
- ភ្នាក់ងារបម្រើអតិថិជន នឹងផ្តល់ពាក្យស្នើសុំឥណទានគេហដ្ឋានទៅកាន់អតិថិជនណាដែលមានបំណងខ្ចីពិតប្រាកដ បន្ទាប់មកជម្រាបប្រាប់ពីលិខិតស្នាមចាំបាច់ដែលជាតម្រូវការរបស់ធនាគារ ជាពិសេសគេហដ្ឋានដែលត្រូវទិញត្រូវតែមានធានារ៉ាប់រង។
- ប្រសិនបើ ពាក្យចុះឈ្មោះសុំឥណទានមានការបំពេញមិនទាន់គ្រប់ តែមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ទៅតាមលក្ខខណ្ឌចាំបាច់ នោះផ្នែកដែលនៅខ្វះខាត ភ្នាក់ងារបម្រើអតិថិជននឹងជួយបំពេញបន្ថែមជូន។
- ក្រោយពេលទទួលបានពាក្យស្នើសុំឥណទានគេហដ្ឋាន ដោយមានការបំពេញត្រឹមត្រូវពីអតិថិជនរួចរាល់ ភ្នាក់ងារបម្រើអតិថិជននឹងបញ្ជូនពាក្យទាំងនោះព្រមទាំងឯកសារដែលជាតម្រូវការរបស់ធនាគារ ទៅដាក់ក្នុងប្រអប់ឯកសាររបស់ភ្នាក់ងារឥណទានទទួលខុសត្រូវ។
- ប្រសិនបើអតិថិជនមិនទាន់បានភ្ជាប់ជាមួយឯកសារដែលជាតម្រូវការរបស់ធនាគារទេ នោះភ្នាក់ងារបម្រើអតិថិជនត្រូវតែបញ្ជាក់ប្រាប់អតិថិជនម្តងទៀត គឺត្រូវរកឯកសារឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធនាគារជាមុនសិន ព្រោះថាប្រសិនបើ ភ្នាក់ងារបម្រើអតិថិជនទទួលនូវឯកសារមិនគ្រប់គ្រាន់ អាចបណ្តាលឲ្យមានការខនខាន និងមានការយឺតយ៉ាវទាំងអតិថិជន និងក្រុមការងារពីព្រោះ ពាក្យស្នើសុំឥណទានដែលមានលក្ខណៈមិនគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌរបស់ធនាគារទេ នោះនឹងត្រូវស្វែងរកឲ្យបានគ្រប់គ្រាន់ម្តងទៀតជាក់ជាមិនខាន។
- អ្នកស្នើសុំឥណទានគេហដ្ឋានអាចទាក់ទងដាក់ពាក្យជាមួយភ្នាក់ងារឥណទានតាមរយៈទូរស័ព្ទ ឬទំនាក់ទំនងដោយផ្ទាល់នៅពេលភ្នាក់ងារឥណទានបានចុះទៅតាមមូលដ្ឋានរបស់អតិថិជន។
- បុគ្គលិកឥណទានត្រូវជំរាបជូនពីលិខិតស្នាមចាំបាច់ដែលជាតម្រូវការរបស់ធនាគារដូចជា៖
  - **សម្រាប់អតិថិជនដែលជាអាជីវករ**
    - ផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុមួយឆ្នាំមុន ឬឆ្នាំចុងក្រោយ
    - ផ្តល់រូបថត ទីតាំងអាជីវកម្មដែលកំពុងតែធ្វើអាជីវកម្ម
    - មានសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬលិខិតផ្សេងៗដែលអាចជំនួសគ្នាបាន
    - ករណីមានជួលទ្រព្យសម្បត្តិអោយអ្នកដទៃ ត្រូវថតចម្លងកិច្ចសន្យាបច្ចុប្បន្ន និងកិច្ចសន្យាជួលផ្សេងៗក្នុងរយៈពេលយ៉ាងហោចណាស់មុនមួយឆ្នាំ ( ប្រសិនបើមាន )
    - សាកសួរអំពីទីតាំង ប្រភេទ និងតម្លៃគេហដ្ឋានដែលទិញ ឬសាងសង់

- ពន្យល់ពីចំណុចសំខាន់ៗនៃគោលការណ៍ប្រតិបត្តិឥណទានគេហដ្ឋាន និងលក្ខខណ្ឌមួយចំនួនពីការខ្ចីប្រាក់
- ភ្នាក់ងារបម្រើអតិថិជន ឬភ្នាក់ងារឥណទាន ត្រូវផ្តល់ពាក្យសុំពាក្យចុះឈ្មោះប្រើប្រាស់សេវាឥណទានជូនទៅអ្នកសុំចុះឈ្មោះដើម្បីបំពេញព័ត៌មាន ឬជួយបំពេញ។ ពេលបំពេញរួចរាល់ហើយឲ្យអ្នកសុំចុះឈ្មោះផ្ដិតមេដៃលើពាក្យស្នើសុំ និងទទួលពាក្យចុះឈ្មោះប្រើប្រាស់សេវាឥណទាន ននិងឯកសារដែលពាក់ព័ន្ធ
- ភ្នាក់ងារបម្រើអតិថិជនត្រូវបញ្ជូនឯកសារទៅឲ្យភ្នាក់ងារឥណទានដើម្បីចុះពិនិត្យ អង្កេត និងធ្វើការវាយតម្លៃឥណទានគេហដ្ឋាន
- ករណីប្រើប្រាស់កម្ចីសម្រាប់សាងសង់គេហដ្ឋានលើទឹកដីកម្មសិទ្ធដែលមានស្រាប់ អ្នកចុះឈ្មោះខ្ចីប្រាក់ត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយសាងសង់គេហដ្ឋាន
- ភ្នាក់ងារឥណទានចុះពិនិត្យ សិក្សា និងវាយតម្លៃលើការសាងសង់
- ករណីអ្នកចុះឈ្មោះមិនទាន់មានគម្រោងចំណាយសាងសង់ ភ្នាក់ងារបម្រើអតិថិជនត្រូវទទួលយកតែពាក្យសុំចុះឈ្មោះសិន ប៉ុន្តែត្រូវប្រាប់អ្នកដាក់ពាក្យសុំចុះឈ្មោះនោះឲ្យរៀបចំគម្រោងចំណាយសាងសង់ ដើម្បីត្រៀមទុកប្រគល់ជូនភ្នាក់ងារឥណទាននៅពេលដែលភ្នាក់ងារឥណទានចុះទៅដល់ទីកន្លែង។

- **ដំណាក់កាលទី២: ការចុះពិនិត្យ និងវាយតម្លៃឥណទាន**

ក្រោយពីទទួលបានពាក្យចុះឈ្មោះសុំខ្ចីឥណទានគេហដ្ឋាន ភ្នាក់ងារឥណទានត្រូវចុះទៅជួបអតិថិជន ឬភាគីអ្នកខ្ចីដល់ផ្ទះ ឬទីកន្លែងដែលបានណាត់ជួប ដើម្បីសាកសួរប្រមូលព័ត៌មានពីតម្រូវការឥណទានគេហដ្ឋាន ព្រមទាំងអង្កេតពិនិត្យសិក្សាស្វែងយល់ពីមុខរបរ ដើម្បីធ្វើការវាយតម្លៃពី លទ្ធភាពនៃការសងត្រឡប់មកវិញរបស់អតិថិជន។ ភ្នាក់ងារឥណទានក៏បានចុះទៅមើលដោយផ្ទាល់ជាមួយអតិថិជនទៅលើគេហដ្ឋានដែលបម្រុងនឹងទិញដើម្បីអាចឲ្យដឹងកាន់ច្បាស់ថា តម្លៃគេហដ្ឋាននោះពិតជាត្រឹមត្រូវទៅតាមពាក្យដែលអតិថិជនបានបំពេញពាក្យសុំ ម៉្យាងទៀតគឺអាចងាយស្រួលដល់ភ្នាក់ងារឥណទានធ្វើការវាយតម្លៃផ្ទះទៅថ្ងៃអនាគត ព្រោះគេហដ្ឋានដែលបម្រុងនឹងទិញនោះគឺជាវត្ថុបញ្ចាំរបស់អតិថិជន ហើយអាចជៀសវាងនូវករណីដែលអតិថិជនមិនសងបំណុលត្រឡប់មកវិញ។

- ភ្នាក់ងារឥណទានត្រូវតែយកចិត្តទុកដាក់លើសិក្សាវាយតម្លៃ ផ្តោតអារម្មណ៍សាកសួរព័ត៌មានពីភាគីខ្ចី ដែលទាក់ទងនឹងព័ត៌មានផ្នែកគុណភាព ព័ត៌មានផ្នែកបរិមាណ តម្រូវការឥណទាន គោល

បំណងនៃការប្រើប្រាស់ប្រាក់កម្ចី ព្រមទាំងព័ត៌មានអំពីទ្រព្យ និងសាកសួរពីកត្តាទាំងឡាយដែលជះឥទ្ធិពលលើមុខរបរ ឬប្រភពចំណូល ឬទ្រព្យ ដែលជាហេតុបង្ករឲ្យមានហានិភ័យ

- ភ្នាក់ងារឥណទានត្រូវបានធ្វើការត្រិះរិះពិចារណាសិក្សាវិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានទាំងនោះថា តើពិតជាត្រឹមត្រូវអាចជឿជាក់សម្រាប់ការធ្វើការវាយតម្លៃទៅលើលទ្ធភាពសង និងតម្រូវការឥណទានហើយឬនៅ?
- ករណីព័ត៌មានមិនមានគ្រប់គ្រាន់ មិនអាចធ្វើការវាយតម្លៃ ឬសម្រេចក្នុងការរៀបចំឯកសារឥណទានបាន ភ្នាក់ងារឥណទានត្រូវចុះទៅសិក្សាស្រាវជ្រាវប្រមូលឥណទានបន្ថែម នឹងត្រូវតែរក្សាអាថ៌កំបាំងវិជ្ជាជីវៈជៀសវាងការបង្ករកើតហេតុមិនល្អ
- ភ្នាក់ងារឥណទានត្រូវទទួលបន្ទុកជួយអ្នកខ្ចី ឬភាគីខ្ចី ដើម្បីពន្យល់នូវនីតិវិធី លក្ខខណ្ឌនៃការខ្ចី ការសងប្រាក់រយៈពេលខ្លី ឬវែង អត្រាការប្រាក់ សាហ៊ុយ ចំណាយទទួលឥណទាន ការបង់ធានារ៉ាប់រង ការទទួលកម្មសិទ្ធគេហដ្ឋានលើទ្រព្យដែលនឹងទទួលត្រូវមានភាពច្បាស់លាស់ ជៀសវាងមានភាពស្រពេចស្រពិលមុនពេលរៀបចំឯកសារឥណទានគេហដ្ឋាន
- ភ្នាក់ងារឥណទានអាចជួបជាមួយនឹងអ្នកលក់គេហដ្ឋាន ឬម្ចាស់សំណង់គេហដ្ឋាន ដើម្បីសាកសួរព័ត៌មានអំពីគេហដ្ឋាន ឬអាចជួបជាមួយនឹងអ្នកលក់ដទៃទៀត ដើម្បីសាកសួរព័ត៌មានបន្ថែមឲ្យកាន់តែច្បាស់
- ក្រោយពីបានធ្វើការវាយតម្លៃលើលទ្ធភាពរបស់អតិថិជន ភ្នាក់ងារឥណទានត្រូវបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាពដែលអាចទទួលឥណទានបានតាមលក្ខខណ្ឌនៃឥណទាន និង បណ្ដុះវិស័យឥណទាន។

- **ដំណាក់កាលទី៣: ការអនុម័តឥណទាន**
  - ភ្នាក់ងារឥណទានទទួលបន្ទុក ត្រូវបញ្ជូនរាល់ឯកសារខ្ចីប្រាក់ទាំងអស់ទៅឲ្យផ្នែករដ្ឋបាល ដើម្បីដាក់ជូនប្រធានភ្នាក់ងារឥណទានធ្វើការត្រួតពិនិត្យ និងជូនថ្នាក់មានសមត្ថកិច្ចអនុម័ត។ បន្ទាប់ពីថ្នាក់មានសមត្ថកិច្ចអនុម័ត ផ្នែករដ្ឋបាលនឹងបញ្ជូនឯកសារទាំងនោះត្រឡប់មកឲ្យភ្នាក់ងារឥណទានទទួលបន្ទុកវិញ ដើម្បីធ្វើការអនុវត្តបន្ត។ ចំពោះទំហំឥណទានដែលមានទំហំក្រោម៥០០០០ដុល្លារអាមេរិក ត្រូវមានសិទ្ធសម្រេចឥណទានដោយអនុប្រធានខ្នាតតូច។ រីឯឥណទានដែលមានទំហំចាប់ពី៥០០០០ដុល្លារអាមេរិកឡើងទៅ ត្រូវធ្វើការអនុម័តដោយប្រធានឥណទានខ្នាតមធ្យម ឬធំ។
- **ដំណាក់កាលទី៤: ការបើកប្រាក់**

- បន្ទាប់ពីឯកសារត្រូវបានចុះហត្ថលេខាពីថ្នាក់លើដែលមានសមត្ថកិច្ចចប់សព្វគ្រប់រួចហើយ និងមានគ្រប់គ្រាន់ដូចជា កិច្ចសន្យាខ្ចីប្រាក់ជាដើម នោះការបើកប្រាក់នឹងអាចដំណើរការទៅបាន។ ធនាគារនឹងបើកប្រាក់កម្ចី ដោយផ្ទេរពីគណនីរបស់ធនាគារតែមួយលើក ឬតាមដំណាក់កាលតែមិនលើសពីបីលើកឡើយដើម្បីដាក់ចូលក្នុងគណនីរបស់អតិថិជនដើម្បីដកប្រាក់ទៅទូទាត់ជាមួយភាគីអ្នកលក់ផ្ទះ ឬសំណង់ដែលសាងសង់លើដីកម្មសិទ្ធដោយផ្អែកទៅតាមកិច្ចព្រមព្រៀងទូទាត់លើការទិញលក់គេហដ្ឋាន និងកិច្ចសន្យាកក់ប្រាក់ ឬសាងសង់តាមអនុលោមតាមកិច្ចព្រមព្រៀង។ ក្នុងករណីនេះ ធនាគារក៏អាចទូទាត់ជាសាច់ប្រាក់ ឬផ្ទេរចូលក្នុងគណនីទៅឲ្យភាគីអ្នកលក់ក៏បានដែរប្រសិនបើជាការស្នើសុំរបស់អតិថិជនរបស់ធនាគារ។

- **ដំណាក់កាលទី៥: ការទូទាត់សងបំណុល**
  - ក្នុងការសងត្រឡប់មកវិញរបស់អតិថិជន ធនាគារបានតម្រូវឲ្យអតិថិជនបើកគណនីធនាគារមួយនៅក្នុង ABA បន្ទាប់មកការសងបំណុលគឺតម្រូវឲ្យយកប្រាក់បញ្ចូលក្នុងគណនីនោះ រួចធនាគារនឹងធ្វើការកាត់ប្រាក់របស់អតិថិជនទាំងការ ទាំងដើម ជាប្រចាំខែរហូតដល់កាលកំណត់នៃកិច្ចសន្យា។ ករណីអតិថិជនមិនមានប្រាក់ក្នុងគណនី គឺមានន័យថាអតិថិជនមានការយឺតយ៉ាវក្នុងការសងត្រឡប់ ឬមានការភ្លេច ដូចនេះបុគ្គលិកធនាគារនឹងទាក់ទងទៅអតិថិជន ដើម្បីរំលឹកដល់អតិថិជនឲ្យធ្វើការបញ្ចូលប្រាក់ទៅក្នុងគណនី។ ក្នុងករណីនេះ ធនាគារក៏មានការផាកពិន័យចំពោះអតិថិជនដែលមានការយឺតយ៉ាវក្នុងការសងត្រឡប់មកវិញផងដែរ។

## ៣.៤.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

ដើម្បីបង្ហាញពីគុណភាពទ្រព្យសកម្មរបស់ធនាគារ និងការពារឥណទានបាត់បង់នាពេលអនាគត គ្រប់ធនាគារត្រូវតែធ្វើចំណាត់ថ្នាក់ឥណទាន និងរក្សានូវសំវិធានធនឥណទានបាត់បង់ឲ្យស្របទៅនឹងតម្រូវការបទបញ្ញត្តិ។ ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ត្រូវបានអនុវត្តតាមគោលការណ៍គ្រប់គ្រងហានិភ័យឥណទាន។

ធនាគារ ABA សាខាខេត្តពោធិ៍សាត់ ក៏មានការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនផងដែរ គឺក្នុងគោលបំណងដើម្បីពង្រឹងវិន័យឥណទាន និងរចនាសម្ព័ន្ធដើមទុនរបស់ធនាគារ។

### ៣.៤.១.ការធ្វើចំណាត់ថ្នាក់ឥណទាន

#### ៣.៤.១.១.និយមន័យ

ការធ្វើចំណាត់ថ្នាក់ឥណទាន គឺជាការចាត់ថ្នាក់គ្រប់ឥណទានទាំងអស់របស់ធនាគារ ABA ផ្អែកលើសមត្ថភាពសងរបស់ខ្ចី។ សមត្ថភាពសងនេះត្រូវបានវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- គុណភាពនៃការរៀបចំឯកសារ

**៣.៤.១.២.ប្រភេទនៃចំណាត់ថ្នាក់ឥណទាន**

ចំណាត់ថ្នាក់ឥណទានត្រូវបានបែងចែកជា៥ប្រភេទដូចខាងក្រោម៖

1. **<u>ធម្មតា (Normal)</u>**: ឥណទានដែលមានការសងទៀងទាត់ ឬហួសកាលកំណត់សងតិចជាង៣០ថ្ងៃ (ពី ០ថ្ងៃ ទៅ ២៩ថ្ងៃ)។
2. **<u>ឃ្លាំមើល (Special mention)</u>**: ឥណទានដែលមានការសងត្រឡប់ហួសកាលកំណត់សង ចំនួន៣០ថ្ងៃ ឬលើសនេះ ប៉ុន្តែតិចជាង៩០ថ្ងៃ ត្រូវបានចាត់ទុកថាជាឥណទានឃ្លាំមើល (ពី៣០ថ្ងៃ ទៅ ៨៩ថ្ងៃ)។
3. **<u>ក្រោមស្តង់ដារ (Sub-standard)</u>**: ឥណទានដែលមានការសងត្រឡប់ហួសកាលកំណត់សង ចំនួន ៩០ថ្ងៃ ឬលើសនេះ ប៉ុន្តែតិចជាង១៨០ថ្ងៃ ត្រូវបានចាត់ទុកថាជាឥណទានក្រោមស្តង់ដារ (ពី៩០ថ្ងៃ ទៅ ១៧៩ថ្ងៃ)។
4. **<u>សង្ស័យ (Doubtful)</u>**: ឥណទានដែលមានការសងត្រឡប់ហួសកាលកំណត់សង ចំនួន១៨០ថ្ងៃ ឬលើសនេះ ប៉ុន្តែតិចជាង៣៦០ថ្ងៃ ត្រូវបានចាត់ទុកថាជាឥណទានសង្ស័យ (ពី១៨០ថ្ងៃ ទៅ ៣៥៩ថ្ងៃ)។
5. **<u>បាត់បង់ (Loss)</u>**: ឥណទានដែលមានការសងត្រឡប់ហួសកាលកំណត់សង ចំនួន៣៦០ថ្ងៃឡើងទៅ ត្រូវបានចាត់ទុកថាជាឥណទានបាត់បង់ (ពី៣៦០ថ្ងៃឡើងទៅ)។

**៣.៤.២.ការធ្វើសំវិធានធន**

ធនាគារត្រូវរក្សាសមវិធានធនសម្រាប់ឥណទានបាត់បង់ឲ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសម្ពាធឥណទានដែលអាចកើតមានឡើង។ សំវិធានធនមាន២ប្រភេទ គឺសំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

**សំវិធានធនសរុប= សំវិធានធនទូទៅ + សំវិធានធនជាក់លាក់**

**៣.៤.២.១.ការធ្វើសំវិធានធនទូទៅ**

សំវិធានធនទូទៅ គឺជាសំវិធានធនដែលធនាគាររក្សាទុក ១%នៃប្រាក់ដើម សម្រាប់ឥណទានទាំងឡាយណាដែលខកខានសងពី សូន្យថ្ងៃដល់២៩ថ្ងៃ (ឥណទានថ្នាក់ធម្មតា)។

**៣.៤.២.២.សំវិធានធនជាក់លាក់**

សំវិធានធនជាក់លាក់ ជាសំវិធានធនដែលធនាគាររក្សាទុកៈ

- ៣% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់ឃ្លាំមើល
- ២០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់ក្រោមស្តង់ដារ
- ៥០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់សង្ស័យ
- ១០០% នៃប្រាក់ដើម សម្រាប់ឥណទានថ្នាក់បាត់បង់។

## ៣.៥.ការគ្រប់គ្រងហានិភ័យឥណទានគេហដ្ឋាន

### ៣.៥.១.និយមន័យហានិភ័យឥណទាន

ហានិភ័យឥណទាន គឺសំដៅទៅលើហានិភ័យនៃការខកខានបង់ដោយសារអតិថិជនដែលជាអ្នកខ្ចីមិនមានមិនមានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចសងការប្រាក់ ទៅតាមកិច្ចសន្យារបស់ខ្លួន។ ហានិភ័យឥណទានគឺជាហានិភ័យមួយប្រភេទដែលគ្រប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់តែងតែយកចិត្តទុកដាក់ជាងគេ ពីព្រោះវាអាចជម្រុញឲ្យស្ថាប័នទាំងនោះក្ស័យធនបាន។ ដូចនេះមុននឹងសម្រេចចិត្តផ្តល់ឥណទានគ្រប់ស្ថាប័នទាំងនោះ តែងតែសិក្សាទៅលើហានិភ័យឥណទាជាចម្បង រហូតដល់គេឃើញថាគ្មានហានិភ័យឥណទាន ឬហានិភ័យឥណទានទាបទើបស្ថាប័នទាំងនោះព្រមផ្តល់កម្ចីឲ្យ។

សរុបមកហានិភ័យឥណទាន គឺជាអ្វីទាំងឡាយណាដែលអាចកើតឡើងចំពោះធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើឲ្យធនាគារ និងគ្រឹះស្ថានទាំងនោះទទួលរងនូវការខូចខាតដោយសារអតិថិជនរបស់ខ្លួនមិនបានសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន ឬមិនសងគ្រប់ចំនួនទាំងដើមនិងការប្រាក់។

### ៣.៥.២.មូលហេតុនៃហានិភ័យឥណទាន

ហានិភ័យឥណទានអាចកើតឡើងអាស្រ័យដោយកត្តា ៣ យ៉ាងគឺៈ

**ក. កត្តាអតិថិជន**

- ការធ្វើការពិចារណាមិនបានដិតដល់ទៅលើការវនិយោគណាមួយ ឬចូលចិត្តការវិនិយោគដែលមានផលចំណេញច្រើន។
- ការយល់ពីលក្ខខណ្ឌឥណទានខុស ការមិនយកចិត្តទុកដាក់របស់អតិថិជនដែលធ្វើឲ្យមិនដឹងពីលក្ខខណ្ឌនានាដូចជាមិនបានដឹងពីគម្រោងនៃការសងបំណុល ឬបាត់វិក័យបត្រជាដើម។
- អ្នកខ្ចីមានគំនិតផ្តេកផ្តួលមិនចងសងបំណុល មិនគោរពតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀង និងព្យាយាមបង្កើតនៅបញ្ហាដើម្បីពន្យាពេលនៃការសង។

- ការប្រើប្រាស់ខុសគោលដៅ អតិថិជនមួយចំនួនប្រើប្រាស់ឥណទានដែលបានផ្តល់ឲ្យខុសគោលដៅ ដោយមិនយកឥណទានទាំងនោះ ទៅប្រើប្រាស់តាមគោលបណងដែលបានខ្ចីតែបែរជា យកកម្ចីទាំងនោះទៅប្រព្រឹត្តល្បែង ឬអំពើខុសច្បាប់ផ្សេងៗ។
- អតិថិជនមានទំនាស់ក្នុងគ្រួសារធ្ងន់ធ្ងរ មានការបែកបាក់គ្នាហើយម្នាក់ៗមិនទទួលខុសត្រូវលើបំណុលដែលកំពុងជំពាក់។

**ខ. កត្តាធនាគារផ្ទាល់**

- កើតឡើងដោយអ្នកឲ្យខ្ចី និងបុគ្គលដែលពាក់ព័ន្ធមិនបានយកចិត្តទុកដាក់លើការងាររបស់ខ្លួន ដូចជាភ្នាក់ងារឥណទានវាយតម្លៃប្រាក់កម្ចីមិនបានត្រឹមត្រូវ និងសិក្សាមិនបានលម្អិតពីប្រវិត្ត និង អត្តចរិកអ្នកខ្ចី លំហូរសាច់ប្រាក់ លទ្ធភាពសង និងហានិភ័យដែលពាក់ព័ន្ធផ្សេងៗ។
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន និង ត្រួតពិនិត្យបំណុលឲ្យទាន់ពេលវេលា។
- ភ្នាក់ងាតឥណទានមិនបានយកចិត្តទុកដាក់បំពេញឯកសារឥណទានឲ្យបានត្រឹមត្រូវ ឬមិនបានបង្កើតជាកិច្ចព្រមព្រៀងនានា ដើម្បីជំនួញ និងភស្តុតាងក្នុងការដោះស្រាយបំណុល។
- បុគ្គលិកមិនមានភាពស្មោះត្រង់

**គ. កត្តាសង្គម និងធម្មជាតិ**

- សង្គម៖ សង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាក់ផ្លូររដ្ឋាភិបាល នយោបាយសេដ្ឋកិច្ច
- វិបត្តិសេដ្ឋកិច្ច៖ កាលណាមានវិបត្តសេដ្ឋកិច្ចកើតឡើងនាំឲ្យក្រុមហ៊ុន សហគ្រាសអាជីវកម្មត្រូវប្រឈមមុខនឹងការក្ស័យធន ព្រោះតម្រូវការអតិថិជនមានការធ្លាក់ចុះដែលជាហេតុបណ្តាល ឲ្យចំណូលផ្ទាល់ខ្លួន និងចំណូលក្រុមហ៊ុនធ្លាក់ចុះ ដូចជាក្រុមហ៊ុន ឬម្ចាស់អាជីវកម្មមិនមានលទ្ធភាពសងបំណុលមកធនាគារវិញ។
- គ្រោះធម្មជាតិ៖ ខ្យល់ព្យុះ គ្រោះទឹកជំនន់ ភ្លើងឆេះផ្ទះ គ្រោះរាំងស្ងួត និងបាតុភូតធម្មជាតិផ្សេងៗដែលនាំឲ្យអតិថិជន បាត់បង់នូវលទ្ធភាពសង។

### ៣.៥.៣.វិធីសាស្រ្តកាត់បន្ថយហានិភ័យឥណទាន

ដើម្បីគ្រប់គ្រងឥណទានឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយនូវហានិភ័យធនាគារ ABA បានសិក្សាទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ក. ចំពោះអតិថិជន**

1. មុនពេលផ្តល់ឥណទាន : មន្ត្រីឥណទានត្រូវប្រមូលព័ត៌មានអំពីអតិថិជនឲ្យបានច្បាស់លាស់ ដោយធ្វើការស៊ើបសួរព័ត៌មាន អំពីសំណាក់អាជ្ញាធរ មានសមត្ថកិច្ច អ្នកជិតខាង ក៏ដូចជាអតិថិជនផ្ទាល់ ទាក់ទងទៅនិងគោលបំណងសុំខ្ចីឥណទាន ទ្រព្យធានា ចំណូលចំណាយ ស្ថានភាពគ្រួសារជាដើម ហើយធ្វើការវាយតម្លៃព័ត៌មាននោះថាមានភាពលម្អៀងគ្នាដែលរឺទេ?
2. កំឡុងពលផ្តល់ឥណទាន : ផ្តល់ព័ត៌មានដែលទាក់ទងនឹងអត្រាការប្រាក់ របៀបសងប្រាក់ រយៈពេលខ្ចី ការជាកពិន័យ នឹងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការប្រើប្រាស់សេវាឥណទាន។
3. ក្រោយពេលផ្តល់ឥណទាន : មន្ត្រីឥណទានត្រូវតាមដានអតិថិជនរបស់ខ្លួនថាតើការធ្វើអាជីវកម្មរបស់គាត់មានការរីកចម្រើនដែលរឺទេ? តើទ្រព្យធានារបស់គាត់មានការដោះដូរ ឬមានការផ្ទេកម្មសិទ្ធដែររឺទេ? ហើយតើគាត់មានជំពាក់បំណុលផ្សេងទៀតជាមួយគ្រឹះស្ថានផ្សេងដែររឺទេ?

**ខ.ចំពោះធនាគារ**

- ប្រធានសាខាត្រូវពង្រឹង ការអនុវត្តរបស់មន្ត្រីឥណទានក្នុងរបាយការណ៍កម្ចីយឺតយ៉ាវ
- ប្រធានសាខាត្រូវចុះត្រួតពិនិត្យផ្ទាល់ លើស្ថានភាពជាក់ស្តែងរបស់អតិថិជននីមួយៗមុននឹងធ្វើការសម្រេចចិត្ត
- ធ្វើការជ្រើសរើសបុគ្គលិកដែលមានចំណេះដឹងទាក់ទងនឹងឥណទាន
- ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ដាក់ទោសចំពោះបុគ្គលិកដែលសាងកំហុសដដែលៗ
- ធ្វើការលើកទឹកចិត្តបន្ថែម ដូចជា ផ្តល់ប្រាក់រង្វាន់លើប្រាក់បៀវត្ស ឬដំឡើងដំណែងដល់បុគ្គលិកណាដែលបំពេញការងារបានល្អ។

**៣.៥.៤.វិធីសាស្ត្រដោះស្រាយបញ្ហាឥណទានគេហដ្ឋាន**

ការដោះស្រាយបញ្ហាឥណទាន គឺជាការចូលរួមការពារទ្រព្យសកម្មរបស់ធនាគារ។ គោលដៅក្នុងការដោះស្រាយបញ្ហាឥណទាន គឺដើម្បីចូលរួមបង្កើនប្រាក់ចំណេញតាមរយៈ៖

- ការកាត់បន្ថយឥណទានបាត់បង់ឲ្យមកនៅត្រឹមកម្រិតអប្បរមា
- ការត្រួតពិនិត្យការខកខានសង (និងសំវិធានធន) ស្រមតាមគោលដៅប្រាក់ចំណេញ
- ការរក្សាបាននូវអតិថិជនដែលផ្តល់ប្រាក់ចំណេញដល់ធនាគារ
- ការធ្វើប្រតិបត្តិការដោយចំណាយថ្លៃដើមប្រកបដោយប្រសិទ្ធភាព

នៅក្នុងការដោះស្រាយឥណទាន ធនាគារនីមួយៗអាចប្រើប្រាស់នូវមធ្យោបាយផ្សេងៗគ្នាជាច្រអាស្រ័យទៅតាមកម្រិតនៃការខកខានសងប្រាក់ ឬអាកប្បកិរិយារបស់អតិថិជននីមួយៗ។ ជាទូទៅធនាគារ ABA ប្រើប្រាស់នូវមធ្យោបាយក្នុងការដោះស្រាយឥណទានដូចខាងក្រោម៖

1. លិខិតក្រើនរំលឹកឲ្យសងប្រាក់
2. ការទាក់ទងអតិថិជនខកខានសងប្រាក់តាមរយៈការហៅទូរស័ព្ទ
3. ការផ្ញើសារតាមទូរស័ព្ទ
4. ការចុះដល់ទីកន្លែង
5. លិខិតជូនដំណឹងស្តីពីការបង់ផ្តាច់ឥណទាន។

## ៣.៦.ការវិភាគ SWOT

គោលបំណងនៃការវិភាគ SWOT គឺជួយឲ្យធនាគារយល់ដឹងកាន់តែច្បាស់នូវកត្តាដែលមានទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រដែលមានឥទ្ធិពលចំពោះធនាគារ ដើម្បីបង្កើតជាចំណុចខ្លាំងក្នុងការលំអរចំណុចខ្សោយ ការស្វែងរកឱកាស និងជៀសវាងការគំរាមគំហែង ដែលបង្កឲ្យមានមហន្តរាយកាន់តែខ្លាំង ដើម្បីរៀបចំយុទ្ធសាស្ត្រផ្សេងៗ ឲ្យធនាគារកាន់តែមានភាពរីកចម្រើនថែមទៀត។ ដូចនេះដើម្បីឲ្យការវិភាគ SWOT កាន់តែមានភាពជាក់ស្តែងនៅក្នុងធនាគារ ABA ធ្វើការវិភាគដូចខាងក្រោម៖

### ៣.៦.១.ចំណុចខ្លាំង

តាមរយៈការសិក្សាស្រាវជ្រាវពីការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ABA សាខាខេត្តពោធិ៍សាត់សង្កេតឃើញថា ធនាគារ ABA មានចំនុចខ្លាំងជាច្រើនដែលអាចធ្វើឲ្យធនាគារនេះមានភាពរីកចម្រើនដែលក្នុងនោះមានដូចខាងក្រោម៖

- ធនាគារ ABA មានការទទួលស្គាល់ច្រើនពីសំណាក់អតិថិជន
- ធនាគារ ABA មានភាគហ៊ុននិកដ៏រឹងមាំ
- ធនាគារ ABA មានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ផ្តល់ឲ្យអតិថិជន
- ធនាគារ ABA មានវិធីសាស្ត្រច្រើនដើម្បីជាជម្រើសដល់អតិថិជនក្នុងការខ្ចីសង
- ធនាគារ ABA មានការគ្រប់គ្រងល្អ ជាពិសេសសម្បូរទៅដោយបុគ្គលិកដែលមានចំណេះដឹងជំនាញ និងបទពិសោធន៍ខ្ពស់
- ធនាគារ ABA តែងតែមានការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ធនាគារ ABA មានផលិតផល និងសេវាកម្មផ្សេងៗសុទ្ធតែមានគុណភាព និងងាយស្រួលក្នុងការប្រើប្រាស់ដែលធ្វើឲ្យអតិថិជនចាស់នៅតែបន្តប្រើប្រាស់ និងមានអតិថិជនថ្មីកើនឡើងជាលំដាប់ ។

**៣.៦.២.ចំណុចខ្សោយ**

ទន្ទឹមជាមួយនិងការរីកចម្រើន និងមានចំណុចខ្លាំងជាច្រើន ធនាគារ ABA ក៏នៅមានចំណុចខ្សោយមួយចំនួនផងដែរដូចជា៖

- ធនាគារ ABA មានលក្ខខណ្ឌ និងមានដំណាក់កាលច្រើនក្នុងការផ្តល់ប្រាក់កម្ចីទៅកាន់អតិថិជន
- ទំហំកម្ចីរបស់ធនាគារ ABA នៅមានកម្រិត
- ចំពោះអត្រាការប្រាក់ហាក់ដូចជាខ្ពស់បន្តិច។

**៣.៦.៣.ឱកាស**

ចំណុចដែលជាឱកាសរបស់ធនាគារ ABA មានដូចជា៖

- ធនាគារ ABA មានសេវាកម្មផ្ទេរប្រាក់ និងដកប្រាក់ ដែលផ្តលភាពងាយស្រួលដល់អតិថិជន
- កម្មវិធី Mobile App ដូចមានធនាគារមួយជាប់ខ្លួន ព្រោះអាចផេរប្រាក់ពីគណនីមួយ ទៅគណនីមួយ បង់ថ្លៃទឹក ភ្លើង ទិញកាតទូរស័ព្ទយ៉ាងស្រួលដោយមិនអស់ថ្លៃសេវាទៀតផង អាចផេរប្រាក់ទៅក្រៅប្រទេស ជាពិសេសផេរទៅសាច់ញាតិ បងប្អូនដែលគាត់មិនមានគណនីនៅ ABA ក៏បាន ដោយប្រើតាម E- Cash កត្តាទាំងនេះហើយដែលធ្វើឲ្យធនាគារ ABA មានឱកាសក្នុងការប្រកួតប្រជែងលើទីផ្សារ។
- ឈានមកដល់សព្វថ្ងៃនេះ ធនាគារ ABA កាន់តែមានការទទួលស្គាល់ និងមានការគាំទ្រពីគ្រប់មជ្ឈដ្ឋានមានដូចជា ស្ថាប័នរដ្ឋ និងឯកជន ក្រុមហ៊ុន អតិថិជនក្នុងស្រុក និងក្រៅស្រុកច្រើន ដូចនេះ ធនាគារ ABA អាចអភិវឌ្ឍន៍ខ្លួនក្លាយជាធនាគារដ៏ធំជាងគេនៅក្នុងស្រុក។

**៣.៦.៤ .ការគំរាមគំហែង**

ក្រៅពីចំណុចមានឱកាសហើយ ធនាគារ ABA ក៏ប្រឈមមុខនឹងការគំរាមគំហែងដែលបណ្តាលមកពីកត្តាផ្សេងៗជាច្រើនដូចជា៖

- ការកើនឡើងនៅធនាគារ ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើឲ្យធនាគារ ABA មានដៃគូរប្រកួតប្រជែងកាន់តែច្រើន
- ការប្រកួតប្រជែងលើអត្រាការប្រាក់
- បច្ចុប្បន្នកំពុងតែមានជំងឺរាតត្បាតសាកលគឺជំងឺ Covid-19 ជាកត្តាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផ្នែកសេដ្ឋកិច្ច ដែលអាចឲ្យមានហានិភ័យកើនឡើង។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីក្រុមនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "ការគ្រប់គ្រងឥណទានគេហដ្ឋាន" របស់ធនាគារ ABA សាខាខេត្តពោធិ៍សាត់កន្លងមក យើងខ្ញុំសង្កេតឃើញថា ឥណទានគេហដ្ឋាន គឺជាផ្នែកមួយនៃប្រាក់ចំណូលរបស់ធនាគារ ដែលបានរួមចំណែកដ៏សំខាន់នៅក្នុងប្រតិបត្តិការរបស់ធនាគារ ហើយក៏បានជួយសម្រេចនូវគោលបំណងជាម្ចាស់កម្មសិទ្ធលើគេដ្ឋានជូនអតិថិជន។ ហេតុដូចនេះហើយទើបធនាគារការគ្រប់គ្រងទៅលើឥណទានគេហដ្ឋាន គឺជាកត្តាដែលចាំបាច់ដែលធនាគារតែងតែខិតខំប្រឹងប្រែង និងយកចិត្តទុក្ខដាក់ក្នុងការអនុវត្តតាមគោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានគេហដ្ឋានបានយ៉ាងខ្ជាប់ខ្ជួន និង ច្បាស់លាស់។

តាមការសិក្សាស្រាវជ្រាវនៅធនាគារ ABA សាខាខេត្តពោធិ៍សាត់យើងខ្ញុំសង្កេតឃើញថាដំណើរការនៃការផ្តល់ និងការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារនេះ គឺមានភាពច្បាស់លាស់ និងត្រឹមត្រូវទៅតាមគោលការណ៍ និងនីតិវិធីរបស់ធនាគារ។ លើសពីនេះទៅទៀត ធនាគារបានបើកឱកាសទូលាយដល់អតិថិជនក្នុងការទទួលឥណទានគេហដ្ឋាន ដែលប្រៀបដូចជាបានជួយជម្រុញនូវចរន្តសេដ្ឋកិច្ចនៅក្នុងប្រទេសឲ្យកាន់តែមានភាពរីកចម្រើន បង្កើតការងារជូនប្រជាជន និងធ្វើឲ្យអតិថិជនមានគេហដ្ឋានសមរម្យតាមគោលបំណង។ ពិសេសជាងនេះទៅទៀត ធនាគារ ABA មានការទទួលខុសត្រូវខ្ពស់ទៅលើការគ្រប់គ្រងឥណទានគេហដ្ឋានដែលទាំងនេះបានបង្ហាញឲ្យឃើញអំពីគុណភាពនៃការប្រតិបត្តិនូវការងារ និងប្រសិទ្ធនៃការប្រើប្រាស់ធនធានរបស់ខ្លួន ដែលក្រៅពីបានទទួលប្រាក់ចំណេញ ប៉ុន្តែថែមទាំងមានមុខងារសំខាន់មួយទៀត គឺជួយអភិវឌ្ឍន៍សង្គមជាតិផងដែរ។

សរុបសេចក្តីមក ការគ្រប់គ្រងឥណទានគេហដ្ឋានរបស់ធនាគារ ABA សាខាខេត្តពោធិ៍សាត់ ពិតជាបានប្រព្រឹត្តទៅយ៉ាងមានគុណភាព និងមានប្រសិទ្ធភាព ដែលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អតិថិជនសង្គមជាតិ និងធនាគារផ្ទាល់។

## ២. អនុសាសន៍

ទន្ទឹមនឹងការរីកចម្រើនក្នុងការផ្តល់ឥណទានគេហដ្ឋានរបស់ធនាគារ ABAសាខាខេត្តពោធិ៍សាត់ យើងសង្កេតឃើញនូវចំណុចខ្វះខាតមួយចំនួនដែលកើតមានផងដែរ។ អាស្រ័យហេតុនេះយើងខ្ញុំសូមផ្តល់ជាគំនិតយោបល់មួយចំនួនជូនចំពោះធនាគារ ក្នុងន័យកែលម្អនូវចំណុចខ្វះខាតទាំងនោះ ដើម្បីឲ្យការប្រតិបត្តិការគ្រប់គ្រងឥណទានគេហដ្ឋានកាន់តែមានប្រសិទ្ធភាព។

- ធនាគារគួរតែពង្រីកបន្ថែមនូវសាខាតាមបណ្តាខេត្ត-ក្រុងនានា ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការស្វែងរកសេវារបស់ធនាគារ។

- ធនាគារគួរតែស្វែងរកដៃគូសហការអាជីវកម្មឲ្យបានច្រើនបន្ថែមទៀត ដែលពាក់ព័ន្ធទៅនឹងវិស័យលំនៅដ្ឋានសម្រាប់ជាជម្រើសដល់អតិថិជនដែលប្រើប្រាស់ឥណទានគេហដ្ឋានរបស់ធនាគារ
- ដោយហេតុថា ការផ្សព្វផ្សាយអំពីឥណទានគេហដ្ឋានរបស់ធនាគារ ABA នៅតាមខេត្តនៅមានកម្រិតនៅឡើយ ដូចនេះធនាគារគួរតែធ្វើការផ្សព្វផ្សាយបន្ថែមអំពីឥណទានគេហដ្ឋាននេះតាមរយៈមន្ត្រីឥណទានឲ្យបានច្រើន។

**ឯកសារយោង**

## ឯកសារជាខេមរភាសា

- សួន ចំរើន, ២០១២, "រូបិយវត្ថុ និងធនាគារ"
- ងួន ហេង, ២០១១, "រូបិយវត្ថុ និងធនាគារ"
- ឈាង ហ៊ុយ, ២០២០, "ការគ្រប់គ្រងឥណទាន"
- ព្រុំ សុគុណ, ២០១២, "Fundamentals of Corporate"
- ម៉ៅ ស្រីអូន និង ស៊ិន ស៊ីណុច, ២០១៩, "សេវាប្រាក់បញ្ញើ-សន្សំ"
- ហុង ម៉ូលីកា និង សឿង សុខឃីម, ២០១៩ "ការគ្រប់គ្រងឥណទានខ្នាតតូច-មធ្យម"
- ម៉ែ សុខជេដ្ឋា, ២០០៥, "ស្ថាប័នហិរញ្ញវត្ថុកម្ពុជា"
- អេង កែវពិសិដ្ឋ, ២០១២, "ការគ្រប់គ្រងឥណទាន"
- រុន សិរីមាលា និង សុខ ថានីន, ២០១១, "ការគ្រប់គ្រងឥណទានខ្នាតតូចបំផុត និងខ្នាតតូច"
- សុខ ចំរើន និង ឡេង សុភក្រ, ២០១៣, "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ"
- កាន់ ដានី និង ឡេង ណាឌី, ២០១២, "នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជក្រៅប្រទេសនៃកម្ពុជា"
- ចាប សុវណ្ណលីដា និង ឡង់ សុធីរ៉ា, ២០១២, "ឥណទានមុខជំនួញខ្នាតតូច"

## ឯកសារគេហទំព័រ

- https://www.ababank.com
- https://www.facebook.com/Khmersarithedu/